LENG NAVATRA CAPITAL PLC

ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃកីថល ម.ក

របាយការណ៍ប្រចាំឆ្នាំ

២០២២

មាតិកា

១- សាវតារស្ថាប័ន..... ១

២- ចក្ខុវិស័យ និងបេសកកម្ម ២

៣- រូបតំណាងនិងពណ៌..... ៣

៤- ក្រុមប្រឹក្សាភិបាល.....៤-៥

៥- សារបស់នាយកប្រតិបត្តិ.....៦-៧

៦- រចនាសម្ព័ន្ធ.....៨

៧- ភាគទុនិក..... ៩

៨- ផលិតផលឥណទាន..... ១០-១៤

៩- ការអភិវឌ្ឍន៍ និង ការគ្រប់គ្រង ធនធានមនុស្ស..... ១៥-១៨

១០-របាយការណ៍របស់ក្រុមប្រឹក្សាភិបាល..... ១៩-២៥

១១-របាយការណ៍របស់ក្រុមសវនករ.....២៦-២៧

១២-របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ.....២៨-២៩

១៣-របាយការណ៍លទ្ធផលលម្អិត..... ៣០

១៤-របាយការណ៍បម្រែបម្រួលមូលធន.....៣១

១៥-របាយការណ៍លំហូរសាច់ប្រាក់.....៣២-៣៣

១៦-កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ.....៣៤-៦០

១.សាវតាស្ថាប័ន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃតីថល ម.ក គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ក្រុមហ៊ុនហ្គ្រាន់ស៊ី ណាវ៉ាត្រា គ្រុប ឯ.ក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃតីថល ម.ក បង្កើតឡើងក្នុងទម្រង់ជា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បានទទួលវិញ្ញាបនបត្របញ្ជាក់ការ ចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០២៧៩១៦ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ចេញដោយក្រសួងពាណិជ្ជកម្ម និង ជាគ្រឹះស្ថានឯកជនដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានហិរញ្ញវត្ថុលេខម.ហ.៨០ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ចេញដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃតីថល ម.ក បង្កើតឡើងក្នុងគោលបំណងផ្តល់ជូននូវផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែបនៅក្នុងប្រទេសកម្ពុជា ដើម្បីជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ ក្នុងការជួយសម្រួលនិងពង្រីកហិរញ្ញប្បទានគាំទ្រដល់តម្រូវការសេវាហិរញ្ញវត្ថុទៅកាន់ ប្រជាពលរដ្ឋដែល មានបំណងចង់បើកអាជីវកម្ម ពង្រីកអាជីវកម្ម ទិញលំនៅដ្ឋាន និងប្រើប្រាស់ផ្ទាល់ខ្លួន។

២.ចក្ខុវិស័យនិងបេសកកម្ម

ចក្ខុវិស័យ

គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ **ឡេង ណាវ៉ាត្រា យ៉ែតធីថល ម.ក** ជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ ប្រកបដោយគុណភាពនិងទំនុកចិត្ត ក្នុងការផ្តល់ជូនសេវាហិរញ្ញវត្ថុដ៏សម្បូរបែប ស្របទៅនឹង តម្រូវការរបស់សាធារណជនទូទាំងប្រទេសកម្ពុជា។

បេសកកម្ម

គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ **ឡេង ណាវ៉ាត្រា យ៉ែតធីថល ម.ក** សេវាហិរញ្ញវត្ថុផ្តល់ជូនសាធារណជន និង សហគ្រាសខ្នាតតូចនិងមធ្យម ស្របទៅតាមតម្រូវការទីផ្សារដើម្បីលើកស្ទួយជីវភាពរស់នៅនិងអាជីវកម្មឲ្យកាន់តែប្រសើរឡើងនៅក្នុងសហគមន៍និងបង្កើនទូវអត្ថប្រយោជន៍ដល់ភាគទុនិកនិងបុគ្គលិកគ្រប់លំដាប់ថ្នាក់

តតិពេចន៍

ឆ្ពោះទៅភាពជោគជ័យជាមួយគ្នា

៣. រូបតំណាងនិងពណ៌

LENG NAVATRA CAPITAL PLC.

នៅចំកណ្តាលនៃរង្វង់អក្សរនិមិត្តសញ្ញានោះមានអក្សរឡាតាំង GALAXY ពណ៌ហាស ដែលបញ្ជាក់ពីភាពបរិសុទ្ធ រឹងមាំ និងមានការរីកលូតលាស់ ប្រកបដោយសុភវិនិច្ឆ័យ ដែលអមជាមួយពណ៌ចំរុះ ស បញ្ជាក់ អំពីអ្នកមានជំនាញ និងទេពកោសល្យល្បីល្បាញរួមបញ្ចូលគ្នា សហការគ្នា ដើម្បីអភិវឌ្ឍសង្គមឆ្ពោះទៅ រកភាពជោគជ័យ ទាំងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស។

៤.ក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ា ឡេង ភត្រា ប្រធានក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ា ឡេង ភត្រា កើតនៅខេត្តព្រៃវែង ក្នុងឆ្នាំ១៩៨៥។ ហើយលោកជាអ្នកជំនួញដែលជោគជ័យម្នាក់នៅកម្ពុជា។លោកបានពង្រីកអាជីវកម្មរបស់លោកតាមរយៈការវិនិយោគជាច្រើនវិស័យផ្សេងៗគ្នានៅកម្ពុជាដែលក្នុងនោះមានវិស័យសំខាន់ៗដូចជាវិស័យសំណង់ រមណីយដ្ឋាន ផ្សារកសិផលធម្មជាតិ ផលិតកម្ម ក៏ដូចជាវិស័យហិរញ្ញវត្ថុជាដើម។

បច្ចុប្បន្នលោកជាអគ្គនាយកក្រុមហ៊ុន ហ្គាឡាក់ស៊ី ណាវ៉ាត្រា គ្រុប ឯ.ក និងជាប្រធានក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេងណាវ៉ាត្រា យ៉ៃភីថល ម.ក ។

ឧកញ៉ា ឡេង បញ្ញាពណ៌ សមាជិកក្រុមប្រឹក្សាភិបាល

ឧកញ៉ា ឡេង បញ្ញាពណ៌ កើតនៅខេត្តព្រៃវែងក្នុងឆ្នាំ១៩៩៦។ លោកស្រីជាអ្នកជំនួញជោគជ័យម្នាក់នៅកម្ពុជា។ លោកស្រីមានបទពិសោធន៍ការងារជាង8ឆ្នាំនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។ បច្ចុប្បន្នលោកស្រីកាន់មុខតំណែងសំខាន់ៗនៅក្នុងក្រុមហ៊ុនហ្គាឡាក់ស៊ី ណាវ៉ាត្រា គ្រុប ឯ.ក និង ជាសមាជិកក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេងណាវ៉ាត្រា យ៉ៃភីថល ម.ក ។

លោកស្រី ម៉ែង ស៊ីដេន សមាជិកក្រុមប្រឹក្សាភិបាល

លោកស្រី ម៉ែង ស៊ីដេន កើតនៅខេត្តព្រៃវែង ក្នុងឆ្នាំ១៩៩៥ ។ លោកស្រីជាអ្នកជំនួញជោគជ័យម្នាក់នៅកម្ពុជា ។ លោកស្រីមានបទពិសោធន์ការងារជាច្រើនឆ្នាំនៅក្នុងវិស័យទីផ្សារ វិស័យអចលើទ្រព្យ និង វិស័យធនាគារ និង ហិរញ្ញវត្ថុ។

បច្ចុប្បន្នលោកស្រីកាន់មុខតំណែងសំខាន់ៗនៅក្នុងក្រុមហ៊ុន ហ្គាឡាក់ស៊ីណាវ៉ាត្រា គ្រុប ឯ.ក និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេងណាវ៉ាត្រា យៃភីថល ម.ក។

លោក សេង សុខុម សមាជិកក្រុមប្រឹក្សា

លោក សេង សុខុម កើតនៅខេត្តកណ្តាល ក្នុងឆ្នាំ១៩៦៨។ ក្នុងវិស័យអប់រំ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត ជំនាញគ្រប់ គ្រងអាជីវកម្មអន្តរជាតិ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ ២០០២។ ថ្នាក់បរិញ្ញាបត្រជំនាញគ្រប់គ្រងអាជីវកម្មអន្តរជាតិ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុង ឆ្នាំ ១៩៩៩ និង ថ្នាក់ទស្សនវិជ្ជា និងចិត្តវិជ្ជា ក្នុងឆ្នាំ ១៩៩៥ ។ លោកបានចាប់ផ្តើមអាជីពការងារដំបូងក្នុងឆ្នាំ១៩៩៥ ជាមួយសហគមន៍អ៊ីរ៉ុប (PRASAC) ក្នុងនាមជាអ្នកសម្របសម្រួល សហគ្រាសខ្នាតតូច និងមធ្យម។ ក្នុងឆ្នាំ២០០០លោកបានបម្រើការងារជាមួយ ក្រុមហ៊ុនស្រាបៀ ថៃហ្គើ ក្នុងនាមជាអ្នកបញ្ជាទិញវត្ថុធាតុដើម។ ក្នុងឆ្នាំ២០០១ លោកបានបម្រើការងារជាមួយធនាគារសហពាណិជ្ជ ក.អ ក្នុងនាមជាប្រធានផ្នែកគ្រប់គ្រង លក់និងទីផ្សារ នៃប័ណ្ណអេឡិកត្រូនិក។ ក្នុងឆ្នាំ ២០០៤ លោកបានបម្រើការងារជាមួយធនាគារវឌ្ឍន: អាស៊ី ចំកាត់ (ABA) ក្នុងនាមជានាយកគ្រប់គ្រងផ្នែកទីផ្សារនិងប្រតិបត្តិការ។ ក្នុងឆ្នាំ២០០៧ លោកបានបម្រើការងារជាមួយធនាគារ CDB ក្នុងនាមជាប្រធានផ្នែកប្រតិបត្តិការ និងជាជំនួយ ការនាយកប្រតិបត្តិ។ ក្នុងឆ្នាំ២០០៩-២០១១ លោកបាន បម្រើការងារជាប្រធានផ្នែកប្រតិបត្តិការនៅធនាគារ ប៊ីយ៉ុងខ្មែរ។ ក្នុងឆ្នាំ ២០១២-២០១៨ លោកជាអគ្គនាយក ក្រុមហ៊ុន អារហ្គ្រោ អ៊ីមផាយ។ ក្នុងឆ្នាំ ២០១៨-២០២០ លោកបានបម្រើការងារជាមួយ ក្រុមហ៊ុន AZI Group ក្នុងនាមជាប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ។ ហើយបច្ចុប្បន្ន លោកជា សមាជិកក្រុមប្រឹក្សាភិបាល និងជានាយកប្រតិបត្តិ របស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម.ក។

៥.សាររបស់នាយកប្រតិបត្តិ

នៅឆ្នាំ២០២២ រិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ នៅលើពិភពលោក មានភាពធូរស្រាល និង ល្អប្រសើរ ដោយសារការចាក់វ៉ាក់សាំង ការគ្រប់គ្រងបាន លើការឆ្លង ការពង្រឹងវិធានការការពារ និងការផ្លាស់ប្តូររបៀបរបបនៃការរស់នៅ ការងារទំនាក់ទំនងសង្គម។

យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ធនាគារជាតិ នៃ កម្ពុជា ទំហំពាណិជ្ជកម្មពិភពលោកបានកើនឡើងវិញក្នុងអត្រា៤,៣% ដែលត្រូវបានគាំទ្រដោយ នយោបាយសារពើពន្ធ និងរូបិយវត្ថុនិងការបន្ធូរបន្ថយវិធានការរឹតត្បិតលើការធ្វើដំណើរ និងប្រកបរបរអាជីវកម្ម។ ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកជាពិសេសប្រទេសអភិវឌ្ឍន៍ដែលជាដៃគូរពាណិជ្ជកម្មសំខាន់របស់កម្ពុជា និង ការរំលត្រលប់មករកភាពប្រក្រតីវិញបន្ទាប់ពីការរីករាលដាលជំងឺកូវីដ-១៩ បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាទទួលបាននូវចំនួនប្រហាក់ប្រហែលក្នុងអត្រា៥.១% ក្នុងឆ្នាំ២០២២ មានការកើនឡើង ២.១% ធៀបនឹងឆ្នាំ២០២១។

ដើម្បីបន្តចូលរួមចំណែកទប់ស្កាត់ ការឆ្លងរីករាលដាលពីជំងឺកូវីដ-១៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ណាវ៉ាត្រា យៃភីថល ម.ក បានអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយគោរពតាមអនុសាស៍របស់រាជរដ្ឋាភិបាលដោយជួយជម្រុញនឹងលើកទឹកចិត្តដល់គណ:គ្រប់គ្រង បុគ្គលិកគ្រប់ជាន់ថ្នាក់ ក្នុងការចូលរួមយុទ្ធនាការចាក់វ៉ាក់សាំងនិងដុសជម្រុញឲ្យបានគ្រប់ៗគ្នា នឹង បន្តអនុវត្តទៅតាមក្រសួងសុខាភិបាល ៣កុំ ៣ការពារ ជាពិសេសបន្តអនុវត្តតាមគោលការណ៍ប្រតិបត្តិស្តង់ដារស្តីពីដំណើរការ និង ការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវ:។

៦- រចនាសម្ព័ន្ធ


ក្រុមប្រឹក្សាភិបាល
(ប្រធាន)
អ្នកឧកញ៉ា ឡេង ឌីណា
ប្រធានាយកប្រតិបត្តិ
សេង សុខុម
អនុប្រធាន
នាយកប្រតិបត្តិ
អ៊ុន សំអុល
គណៈកម្មការ សវនកម្ម
គណៈកម្មការ ហានិភ័យ
គណៈកម្មការ ឥណទាន
នាយកដ្ឋាន ឥណទាន
ស្រី មករា
ផ្នែកគ្រប់គ្រង ឥណទាន
ផ្នែកវិភាគ ឥណទាន
នាយកដ្ឋាន ប្រតិបត្តិការ
ផ្នែកធនធានមនុស្ស
ការិយាល័យ
បណ្ណាធិការ
ផ្នែកលក់/ទីផ្សារ/ឥណទាន
ផ្នែករដ្ឋបាល
នាយកដ្ឋាន ហិរញ្ញវត្ថុ
ម៉ៃ ចាន់ធី
ផ្នែកគណនេយ្យ
នាយកដ្ឋាន
បច្ចេកវិទ្យាព័ត៌មាន
ឃួត ប្រុស
Hardware
Soft Ware
ផ្នែកសវនកម្ម ផ្ទៃក្នុង
សាខា (ក)
សាខា (ខ)
សាខា (គ)
សាខា (ឃ)
សាខា (ង)
សាខា (ច)
ប្រធានផ្នែកប្រតិបត្តិការ
ហ៊ីម ម៉ីនធឿន

៧ . ភាគទុនិក



■ ឡុកញ៉ា ឡេង បញ្ញាពណ៌ ■ លោក សេង សុខុម

ល.រ	ឈ្មោះភាគទុនិក	ចំនួនភាគហ៊ុន	ចំនួនទឹកប្រាក់	ភាគរយ
១	ឡុកញ៉ា ឡេង បញ្ញាពណ៌	១៣.០០០	៣.១៥០.០០០	៧០%
២	លោក សេង សុខុម	២៧.០០០	១.៣៥០.០០០	៣០%
សរុប		៤០.០០០	៤.៥០០.០០០	១០០%

៨. ផលិតផល និងសេវាកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃតីថល ម.ក នឹងផ្តល់ជូននូវផលិតផលឥណទាន និងសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ និងមានគោលដៅចម្បងសំដៅលើការផ្តល់ឥណទានគេហដ្ឋាន និង ដីឡូត៍ដែលមានតម្លៃសមរម្យ នៅប្រទេសកម្ពុជា។ គោលបំណងនៃការបើកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្ទាល់ខ្លួន គឺដើម្បីពង្រីកហិរញ្ញវត្ថុជួយគាំទ្រដល់តម្រូវការក្នុងសាងសង់លំនៅឋាននិងការទិញដីឡូត៍ដែលមានតម្លៃសមរម្យ។

អាជីវកម្មរបស់យើងផ្តល់ជូនដូចខាងក្រោម:

* ផ្តល់ឥណទានជូនអ្នកទិញគេហដ្ឋានដែលជាអតិថិជនចម្បងទៅតាមគម្រោងសាងសង់គេហដ្ឋានតម្លៃសមរម្យនីមួយៗរបស់យើង។
* ផ្តល់ផលិតផលឥណទានសម្ផូរបែប ដើម្បីបំពេញសេចក្តីត្រូវការ និងតម្រូវការក្នុងទីផ្សារ។
* ផ្តល់ជម្រើសតាមសេចក្តីត្រូវការជាមួយនឹងតម្លៃសមរម្យ រួមជាមួយលក្ខខណ្ឌនៃការទូទាត់ដែលមានភាពបត់បែនដល់អតិថិជន។ គ្រឹះស្ថាន ឡេង ណាវ៉ាត្រា យៃតីថល ម.ក មានបម្រើសេវាឥណទានដូចខាងក្រោម:

១)ឥណទានទិញលំនៅដ្ឋាន និងទិញដីឡូត៍

ត្រូវបានផ្តល់ជូនអតិថិជនជាប្រាក់រៀលឬប្រាក់ដុល្លារ ដែលមានទំហំចាប់ពី១៥,០០០ដុល្លារ ឬ ៦០លានរៀលដល់ ១០០,០០០ដុល្លារឬ៤០០លានរៀលមានរយៈពេលដល់១២០ខែ និងអត្រាការប្រាក់ចាប់ពី១២%/ឆ្នាំដល់១៨% /ឆ្នាំ។

២)- ឥណទានអាជីវកម្ម :

ជាប្រាក់រៀលឬប្រាក់ដុល្លារ ដែលមានទំហំចាប់ពី៥,០០០ដុល្លារ ឬ ២០លានរៀល ដល់ ៥០,០០០ដុល្លារ ឬ២០០លានរៀល មានរយៈពេលដល់១២០ខែ និងអត្រាការប្រាក់ចាប់ពី ១២% ឆ្នាំ ដល់ ១៨% ឆ្នាំ។

៣) ឥណទានវិកត្តជន :

ជាប្រាក់រៀលឬប្រាក់ដុល្លារ ដែលមានទំហំចាប់ពី៥,០០០ដុល្លារឬ២០លានរៀល ដល់ ៣០,០០០ដុល្លារឬ១២០លានរៀល មានរយៈពេលដល់១២០ខែ និងអត្រាការប្រាក់ចាប់ពី ១២% ឆ្នាំ ដល់ ១៨% ឆ្នាំ

ដៃគូសហការដើម្បីទូទាត់កម្ចី

- ABA BANK — ធនាគារផ្លាន:អាស៊ីចំកាត់
- Wing Bank — ធនាគារវីង
- ធនាគារ ស្ថាបនា SATHAPANA BANK — ធនាគារស្ថាបនា
- ធនាគារអេស៊ីលីដា

ផែនការទំលាក់ទុនសម្រេចក្នុងឆ្នាំ២០២២

នៅក្នុងឆ្នាំ២០២២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃភីថល ម.ក បានសម្រេចលទ្ធផលលើផលបត្រប្រាក់កម្ចីចំនួន 5,000,000ដុល្លារ និងចំនួនអតិថិជនសកម្ម 426នាក់។

LENG NAVATRA CAPITAL PLC.

ឥណទានទិញលំនៅដ្ឋាន

ផ្តល់កម្ចីរហូតដល់ ១០០,០០០ ដុល្លារ

រយៈពេលរហូតដល់ ១២០ ខែ

ព័ត៌មានបន្ថែម
០២៣ ៩៣ ៤៤៤៤

LENG NAVATRA CAPITAL PLC.

ឥណទានឯកត្តជន

ផ្តល់កម្ចីរហូតដល់ ៣០,០០០ ដុល្លារ

រយៈពេលរហូតដល់ ១២០ ខែ

ព័ត៌មានបន្ថែម
០២៣ ៩៣ ៤៤៤៤

LENG NAVATRA CAPITAL PLC.

ឥណទានអាជីវកម្ម

ផ្តល់កម្ចីរហូតដល់ ៥០,០០០ ដុល្លារ

រយៈពេលរហូតដល់ ១២០ ខែ

ព័ត៌មានបន្ថែម
០២៣ ៩៣ ៤៤៤៤

៩.ការអភិវឌ្ឍន៍ និង ការគ្រប់គ្រង

ការជ្រើសរើសបុគ្គលិកតាមរយៈប្រព័ន្ធ

គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក ស្វាគមន៍រាល់បេក្ខជនដែលមានសមត្ថភាព សក្តានុពល និងប្រកបដោយភាពជឿជាក់ខ្ពស់ បន្តចូលរួមចំណែកក្នុងភាពជោគជ័យរបស់យើង ។ ដូចនេះការជ្រើសរើសបុគ្គលិកដែលមានសមត្ថតភាព និង សក្តានុពល នៅតែជាយន្តការគន្លឹះក្នុងការគាំទ្រដល់ការរីកចម្រើន អាជីកម្មរបស់យើង ជាក់ស្តែង យើងបានបង្កើនចំនួនបុគ្គលិក រហូតដល់ ១៣%បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ-១៩ យើងបានសម្រេច និងវិឌ្ឍន៍ខ្លួនឈានទៅមួយកម្រិតទៀត ទៅក្នុងបរិបទសកលភាវូបនីយកម្ម នៃ ប្រព័ន្ធទំនាក់ទំនងតាមរយៈប្រព័ន្ធឌីជីថលផ្សេងៗ ដើម្បីសម្រួលដល់ដំណើរការជ្រើសរើសបុគ្គលិករបស់យើង។ យើងបានផ្តល់មធ្យោបាយដែលមានភាពបត់បែននិងងាយស្រួលដល់បេក្ខជនក្នុងដំណើរការ នៃ ការសម្ភាសន៍ដោយធ្វើ តាមប្រព័ន្ធឌីជីថល ផ្សេងៗ ដូចជា **Microsoft Team, Zoom** និង **Skype** ជាដើម។ ជាងនេះទៅទៀត យើងក៏បានធ្វើកំណែ ទម្រង់ទាក់ទងទៅនឹងឯកសារចាំបាច់នានា ក្នុងដំណើរការជ្រើសរើស ដោយអនុវត្តតាមប្រព័ន្ធឌីជីថលទាំងអស់រួមមានការដាក់សំណើការអនុម័ត និង ដំណើរការនៃការចាប់ផ្តើមការងាររបស់បុគ្គលិកថ្មី។ នៅ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក យើង តែងតែខិតខំរិះរកនូវមធ្យោបាយថ្មីៗ ដើម្បីសម្រេចកិច្ចការផ្សេងៗ។

ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

កូវីដ១៩ (**Covid**-19) បានផ្តល់ឱ្យយើងនូវឱកាសដើម្បីពង្រឹងនូវការទទួលបានការគាំទ្រ និងការសហការពីភាគីពាក់ពន្ធ័កាន់តែល្អប្រសើរនិងរកឃើញនូវវិធីថ្មីនៃការរៀនសូត្រដើម្បីជាការលើកកម្ពស់ការអភិវឌ្ឍសមត្ថតភាពបុគ្គលិកគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក ។ ខាងក្រោមជាការខិតខំប្រឹងប្រែងមួយចំនួនដែល ក្រុមការងារសម្រេចបាន ។

១-កម្មវិធីអភិវឌ្ឍន៍ ភាសាអង់គ្លេសជ់ជ់ល់បុគ្គលិក

ស្តែងចេញពីភាពចាំបាច់ លើការងារប្រាស្រ័យទាក់ទង ប្រចាំថ្ងៃកម្មវិធី ថ្នាក់ភាសាអង់គ្លេស បានកំពុងបើកទ្វារ សម្រាប់បុគ្គលិក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក ដើម្បី ជួយពួកគាត់ឱ្យត្រៀមខ្លួនទៅនឹងការផ្លាស់ប្តូរអាជីវកម្មថ្មីៗណាមួយ នាពេលខាង មុខ ។ ឆ្នាំ២០២៣ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា បានពង្រីកកម្មវិធីនេះដល់ ប្រធានសាខា និងបុគ្គលិក សក្តានុពលរបស់ខ្លួនផងដែរ។

២- កម្មវិធីបណ្តុះបណ្តាលបុគ្គលិកសក្តានុពល

ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក មានសក្តានុពលត្រូវបានផ្តល់ ការយកចិត្ត ទុកដាក់ខ្លាំងនាពេលបច្ចុប្បន្ន។កម្មវិធីនេះបានផ្តល់ឱ្យបុគ្គលិកទទួល បានភាពស្និទ្ធស្នាល ការលើកទឹកចិត្ត និង មានឱកាសបញ្ចេញសមត្ថភាពជាមួយស្ថាប័នបានយូរ។

២- កម្មវិធីបណ្តុះបណ្តាលបុគ្គលិកសក្តានុពល

គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក ផ្តល់កម្មវិធីជាក់លាក់មួយដើម្បីអភិវឌ្ឍន៍ បុគ្គលិកមានសក្តានុពលរបស់ខ្លួនក្នុងគោលដៅសម្រាប់ ពួកគាត់ ត្រៀមខ្លួនទៅ កាន់តំណែង ថ្មីនិងមានសមត្ថភាពក្នុងការពង្រីកវិសាលភាពការងារបន្ថែម។ ជាក់ស្តែងនាឆ្នាំ ២០២២ វគ្គសិក្សាសំខាន់ៗចំនួន៥ ត្រូវបាន ដាក់បណ្តុះ បណ្តាល និងមានបុគ្គលិកមួយចំនួននឹងបាន ចូលរួមក្នុងកម្មវិធីនេះ។

៣-កម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកថ្មីដោយប្រើវិធី សាស្ត្រផ្គូប

ឆ្នាំ២០២២ ជាឆ្នាំដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក បានដាក់ដំណើរការកម្មវិធីបណ្តុះ បណ្តាលថ្មីសម្រាប់មន្ត្រីទំនាក់ទំនងអតិថិជិន ដែលត្រូវបានជ្រើសរើសថ្មី ។ កម្មវិធីណ្តុះបណ្តាលថ្មីនេះត្រូវបានបង្កើតឡើងដោយផ្គូបនឹងវិធីសាស្ត្រចម្រុះ ផ្អែកលើបទពិសោធន៍ជាគោល។បច្ចុប្បន្ននេះកម្មវិធីត្រូវបានដាក់ឱ្យសិក្សាទៅដល់អ្នករៀនរបស់យើងរួមមានបុគ្គលិកថ្មី ដែលគ្មាននិងឬមានបទពិសោធន៍ និងកម្មវិធី បណ្តុះបណ្តាល មួយចំនួនទៀត ទៅតាមសមត្ថភាពផ្សេងៗគ្នារបស់បុគ្គលិក ។

៤-ការយកចិត្តទុកដាក់បុគ្គលិកតាមរយៈសកម្មភាពសុខុមាលភាពផ្សេងៗ

សុខភាពផ្លូវចិត្តនិងសុខុមាលភាពត្រូវបានកំណត់ជាអាទិភាពសំខាន់ក្នុងបេសកកម្មធនធានមនុស្សរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក ជាពិសេសនៅក្នុងឆ្នាំនេះដោយសារពិភពលោកបានជួបប្រទះវិបត្តិសុខភាពជាសកល ។ ការអូសបន្លាយនៃជំងឺរាតត្បាតកូវីដ -១៩ បានផ្តល់ផលប៉ះពាល់ដល់ជីវភាព សុខភាព ផ្លូវកាយ និង សុខុមាលភាពផ្លូវចិត្តរបស់បុគ្គលិក ។ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក មានចំណាត់ការយ៉ាងច្រើន ដើម្បីគាំទ្រដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាព បុគ្គលិក ដូចខាងក្រោម៖

*ការចាក់វ៉ាក់សាំង ៖ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម.កបានគាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធនាការចាក់ថ្នាំបង្ការ និងលើកទឹកចិត្តឱ្យបុគ្គលិកចាក់ថ្នាំបង្ការដើម្បីបង្កើនភាពស៊ាំនៅក្នុងសហគមន៍។ ជាលទ្ធផល១០០% នៃចំនួនបុគ្គលិកសរុបរបស់ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃភីថល ម . ក បានស្ម័គ្រចិត្តទទួលការចាក់វ៉ាក់សាំងយ៉ាងពេញលេញ ដោយយើងទទួលបានការសម្របសម្រួលពី សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

* ការឧបត្ថម្ភទំនុកបំរុងផ្សេងៗ ៖ ដើម្បីគាំទ្រដល់សុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់បុគ្គលិកយើង អំឡុងពេល ព្យាបាល និងការធ្វើចត្តាឡីស័ក ដោយបានផ្តល់ដូចខាងក្រោម៖

- កញ្ចប់មូលនិធិពិសេសត្រូវបានផ្តល់ជូនបុគ្គលិកដែលមាន ប្តី / ប្រពន្ធ កូន របស់បុគ្គលិកដែលបានឆ្លងកូវីដ-១៩ពីថ្ងៃទី ១ខែឧសភាដល់ថ្ងៃទី ៥ ខែវិច្ឆិកាឆ្នាំ ២០២១។

-ប្រាក់ឧបត្ថម្ភពិសេសសម្រាប់បុគ្គលិកដែលត្រូវបំពេញការងារប្រចាំការ ឬតម្រូវឱ្យធ្វើចត្តាឡីស័កនៅកន្លែងការងារ ឬ នៅក្នុងតំបន់ចិទ្ធ

- អំណោយសួរសុខទុក្ខសម្រាប់បុគ្គលិកដែលកំពុងទទួលការព្យាបាល និង ធ្វើចត្តាឡីស័ក ការធានារ៉ាប់រងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យសម្រាប់បុគ្គលិកនិងអ្នកនៅក្នុងបន្ទុករបស់ពួកគេ ធានារ៉ាបរង អាយុជីវិតសម្រាប់បុគ្គលិកនិងបេឡាជាតិរបបសន្តិសុខសង្គម។

*គោលការណ៍ការពារ ៖ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ឡេងណាវាត្រា យ៉ែតីថលម.ក បានដាក់ចេញនូវ គោលការណ៍ណែនាំ និង យន្តការដ៏ហ្មត់ចត់ដើម្បីគាំពារ បុគ្គលិក និងអតិថិជន របស់ខ្លួន។ រួមមានគោលការណ៍នៅពេលមានបុគ្គលិក ឬ អតិថិជនបានឆ្លងមេរោគកូវីដ-១៩ គោលការណ៍ចត្តាឡីស័ក ការធ្វើការពីផ្ទះ និងច្បាប់ឈប់សម្រាក។ សុវត្ថិភាពនៅកន្លែងធ្វើការជាអាទិភាពចម្បងសំខាន់ទីមួយដោយយើងបានអនុវត្តយ៉ាងហ្មត់ចត់តាមអនុសាសន៍ របស់រាជរដ្ឋាភិបាលកម្ពុជាមានដូចជា៖ការគ្រប់គ្រងការធ្វើតេស្តរហ័ស ការពាក់ម៉ាស់ ស្តេន**QR**កូដ **Covid** និង ត្រួតពិនិត្យសីតុណ្ហភាពជាដើម។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតីថល ម.ក

របាយការណ៍ហិរញ្ញវត្ថុ
និងរបាយការណ៍របស់សវនករឯកអាជ្ញ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

របាយការណ៍ហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីចល ម.ក

របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍របស់សវនករឯករាជ្យ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

ព័ត៌មានរបស់ក្រុមហ៊ុន

ក្រុមហ៊ុន	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីចល ម.ក	
ចុះបញ្ជីពាណិជ្ជកម្មលេខ	00027916	
ទីស្នាក់ការចុះបញ្ជី	ផ្លូវលេខ អូស៊ីអាយស៊ី ភូមិ គៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា	
ភាគទុនិក	ឧកញ៉ា ឡេង បញ្ញាពណ៌ លោក សេង សុខុម	
ក្រុមប្រឹក្សាភិបាល	អ្នកឧកញ៉ា ឡេង ភត្រា	ប្រធានក្រុមប្រឹក្សាភិបាល
	ឧកញ៉ា ឡេង បញ្ញាពណ៌	អភិបាល
	លោក សេង សុខុម	អភិបាល
	អ្នកស្រី ម៉េង ស៊ីដេន	អភិបាល
ធនាគារិកចម្បងៗ	ធនាគារ ស្ថាបនា ភីអ៊ីលស៊ី ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ធនាគារ អេស៊ីលីដា ភីអ៊ីលស៊ី ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ធនាគារ រ៉ីង (ខេមបូឌា) ម.ក	
សវនករ	ម៉ូរីសុនកាក់ អ៊ីមខេអេ	

ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាតាត្រា យ៉ែតីថល អ.ក

របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍របស់សវនករឯករាជ្យ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

មាតិកា

	ទំព័រ
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	១៩-២៥
របាយការណ៍របស់សវនករឯករាជ្យ	២៦-២៧
របាយការណ៍ហិរញ្ញវត្ថុ	
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	២៨-២៩
របាយការណ៍លទ្ធផលលម្អិត	៣០
របាយការណ៍បម្រែបម្រួលមូលធន	៣១
របាយការណ៍លំហូរសាច់ប្រាក់	៣២-៣៣
កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ	៣៤-៦០

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានកិត្តិយសដាក់ជូនពិនិត្យនូវរបាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបានធ្វើសវនកម្មរបស់ក្រុមហ៊ុន **ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាតាត្រា យ៉ែតីថល អ.ក** (លំដាប់នេះតទៅហៅកាត់ថា "ក្រុមហ៊ុន") សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022។

សកម្មភាពចំបង

សកម្មភាពចំបងរបស់ក្រុមហ៊ុនគឺផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗជូនអតិថិជនក្នុងស្រុក តាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងសាខាតាមបណ្តាលខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងឆ្នាំនេះក្រុមហ៊ុនមិនមានការផ្លាស់ប្តូរលក្ខណៈនៃសកម្មភាពចំបង។

លទ្ធផលហិរញ្ញវត្ថុ និង លាភការ

លទ្ធផលហិរញ្ញវត្ថុសំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ត្រូវបានបង្ហាញក្នុងរបាយការណ៍លទ្ធផលលម្អិតនៅទំព័រទី12។

ក្រុមប្រឹក្សាភិបាលមិនបានសំរេចប្រកាស ឬបែងចែកភាគលាភសំរាប់ការិយបរិច្ឆេទនេះទេ។

ដើមទុនលក្ខន្តិក:

ក្នុងកំឡុងឆ្នាំ 2022 ដើមទុនដែលបានបង់រួចរបស់ក្រុមហ៊ុនត្រូវបានកើនឡើងពី 1,500,000 ដុល្លារ ទៅ 4,500,000 ដុល្លារអាមេរិក ដែលមានចំនួន 90,000 ហ៊ុន ដែលមានតម្លៃស្មើ 50 ដុល្លារក្នុងមួយហ៊ុន។ ការបង្កើនដើមទុនត្រូវបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 25 ខែសីហា ឆ្នាំ 2022។ នៅថ្ងៃទី 5 ខែកញ្ញា ឆ្នាំ 2022 ក្រុមហ៊ុនបានទទួលការយល់ព្រមពី ក្រសួងពាណិជ្ជកម្ម ក្នុងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរខាងលើ។

ទុនបម្រុងនិងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ឥណទានជាប់សង្ស័យនិងពិបាកទារ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យទាក់ទងទៅនឹងការលុបចោលឥណទានមិនល្អ ឬការធ្វើសំវិធានធនចំពោះឥណទានដែលជាប់សង្ស័យ និងមានការជឿជាក់ថា ឥណទានអាក្រក់ត្រូវបានគេលុបចោលនិងសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណា មួយដែលនឹងបណ្តាលអោយចំនួននៃឥណទានមិនល្អដែលលុបចោល ឬសំវិធានធនចំពោះបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនគ្រប់គ្រាន់រហូតដល់កំរិតទឹកប្រាក់ជាសារវន្តណាមួយនោះទេ។

ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីធានាថា បណ្តាទ្រព្យសកម្ម ក្រៅពីឥណទាន ដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាអោយបានស្មើនឹងតម្លៃកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយអោយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ។

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើអោយប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនត្រឹមត្រូវជាសារវន្តណាមួយនោះឡើយ។

ផែនទ្រព្យអកម្មនិងទ្រព្យអកម្មផ្សេងៗទៀត

មកដល់ថ្ងៃចេញរបាយការណ៍នេះគឺពុំមាន ៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនដែលកើតមានឡើងនៅដំណាច់ការិយបរិច្ឆេទសំរាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយ ឬ
(ខ) ផែនទ្រព្យអកម្មណាមួយកើតមានឡើងចំពោះក្រុមហ៊ុនចាប់តាំងពីដំណាច់ការិយបរិច្ឆេទក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន និងដូចដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល គឺពុំមានផែនទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុនត្រូវបានទាមទារអោយសង ឬអាចនឹងត្រូវទាមទារអោយសងក្នុងរយៈពេល 12 ខែបន្ទាប់ពីថ្ងៃបញ្ចប់បញ្ជីនៃការិយបរិច្ឆេទដែលនឹងមានការប៉ះពាល់ ឬអាចនឹងមានការប៉ះពាល់ធំដុំដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់។

ការផ្លាស់ប្តូរនៃហេតុការណ៍

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលអោយមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានចំនួនមិនត្រឹមត្រូវជាសារវន្តណាមួយនោះឡើយ។

ប្រការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ពុំមានការប៉ះពាល់ធំដុំដោយប្រការ ឬកិច្ចការជំនួញ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។
ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានប្រការ កិច្ចការជំនួញ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតាបានកើតមានឡើងនៅក្នុងចន្លោះពេលរវាងថ្ងៃបិទបញ្ជីនៃការិយបរិច្ឆេទ និងថ្ងៃចេញរបាយការណ៍នេះដែលអាចនាំអោយប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងឆ្នាំដែលបានរាយការណ៍នេះ។

សមាជិកក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបំរើការក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន ៖

អ្នកឧកញ៉ា ឡេង ភក្រា	ប្រធានក្រុមប្រឹក្សាភិបាល
ឧកញ៉ា ឡេង បញ្ញពណ៌	អភិបាល
លោក សេង សុខុម	អភិបាល
អ្នកស្រី ម៉េង ស៊ីដេន	អភិបាល

ភាគហ៊ុនកាន់កាប់ដោយអភិបាល

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022 នាយកដែលកាន់ការិយាល័យនៅដំណាច់ឆ្នាំហិរញ្ញវត្ថុ និងអ្នកដែលមានដើមទុនរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

	ចំនួនភាគហ៊ុន	ដុល្លារអាមេរិក	%
ឧកញ៉ា ឡេង បញ្ញពណ៌	63,000	3,150,000	70
លោក សេង សុខុម	27,000	1,350,000	30

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងរហូតដល់ចុងការិយបរិច្ឆេទនេះ ពុំមានការព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនចូលរួមជាគូភាគីក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬ លិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (ត)

ចាប់តាំងពីការិយបរិច្ឆេទហិរញ្ញវត្ថុឆ្នាំមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រុមហ៊ុន និងក្រុមប្រឹក្សាភិបាល ឬរវាងក្រុមហ៊ុន និងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក, ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុធំដុំជាមួយ, ដោយឡែកតែប្រតិបត្តិការដូចមានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈកិច្ចធ្វើការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីចង្អុលបង្ហាញនូវទិដ្ឋភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបិទបញ្ជី។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះតំរូវអោយក្រុមប្រឹក្សាភិបាល ៖

ក) អនុវត្តនូវគោលការណ៍គណនេយ្យសមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយបន្ទាប់នោះធ្វើការអនុវត្តគោលការណ៍ទាំងនេះជានិច្ចកាល,

ខ) គោរពតាមគោលការណ៍គណនេយ្យ និងតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs) ហើយប្រសិនបើការស្វែងរកទិដ្ឋភាពពិតប្រាកដតំរូវអោយប្រើវិធានដទៃទៀតដែលខុសពីវិធានមុនៗ វិធានថ្មីនេះត្រូវបានបង្ហាញនិងពន្យល់អោយបានច្បាស់លាស់ និងកំណត់បរិមាណ នៃការប្រែប្រួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ,

គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យអោយបានត្រឹមត្រូវ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងអោយមានប្រសិទ្ធិភាព,

ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មត់ថាក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត, និង

ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនអោយមានប្រសិទ្ធិភាពលើរាល់ការសំរេចចិត្តនិងចាត់វិធានការដែលមានសារៈសំខាន់ដែលប៉ះពាល់ដល់ប្រតិបត្តិការនិងដំណើរការក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុថា ក្រុមហ៊ុនបានអនុវត្តនូវរាល់តំរូវការដូចមានចែងខាងលើ។

សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល

យើងខ្ញុំជាសមាជិកនៃក្រុមប្រឹក្សាភិបាល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃភីថល ម.ក សូមប្រកាសថា តាមយោបល់របស់យើងខ្ញុំ ៖

1) លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 មិនមានការប៉ះពាល់ជាសារវន្តដោយប្រការ ឬកិច្ចការជំនួញ ឬនិងព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ហើយប្រការឬកិច្ចការជំនួញ ឬនិងព្រឹត្តិការណ៍ណាមួយនោះ ក៏ពុំបានកើតមានឡើងនៅក្នុងចន្លោះពេលចាប់ពីថ្ងៃបិទការិយបរិច្ឆេទមកទល់នឹងថ្ងៃចេញរបាយការណ៍នេះទេ ក្រៅពីអ្វីដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ, និង

2) របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលមានភ្ជាប់ ត្រូវបានរៀបចំឡើងដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 និងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃខាងលើ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs)”។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយ ៖

លោក សេង សុខុម
ក្រុមប្រឹក្សាភិបាល
ថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2023

របាយការណ៍របស់សវនករឯករាជ្យ
ជូនចំពោះភាគទុនិក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតមីថល ម.ក

មតិរបស់សវនករឯករាជ្យ

យើងខ្ញុំបានធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតមីថល ម.ក** (លំដាប់នេះតទៅហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ព្រមទាំងរបាយការណ៍លទ្ធផលលម្អិត, របាយការណ៍បម្រែបម្រួលមូលធន, របាយការណ៍លំហូរសាច់ប្រាក់នៃការិយបរិច្ឆេទខាងលើ និងកំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុដោយរួមមានគោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ។

យើងខ្ញុំមានមតិថា លើកលែងតែផលប៉ះពាល់នៃបញ្ហាដែលបានពិពណ៌នានៅក្នុងផ្នែកមូលដ្ឋានលើមតិរបស់សវនករ របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់នេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 និង លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាការិយបរិច្ឆេទខាងលើ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs)។

មូលដ្ឋានលើមតិរបស់សវនករឯករាជ្យ

ដូចមានចែងក្នុងកំណត់សម្គាល់ទី 4 សាច់ប្រាក់ក្នុងដៃដែលបានកត់ត្រានៅចុងការិយបរិច្ឆេទមានចំនួន 30,423 ដុល្លារ។ ប៉ុន្តែ យើងបានរកឃើញថាសមតុល្យដែលបានកត់ត្រានេះ និងសាច់ប្រាក់ពិតប្រាកដនៅក្នុងដៃ គឺមានភាពខុសគ្នា។ ទោះបីជាការកត់ត្រាគណនេយ្យបង្ហាញពីសមតុល្យសាច់ប្រាក់នៅក្នុងដៃក៏ដោយ អ្នកគ្រប់គ្រងបានបញ្ជាក់ថាមិនមានសាច់ប្រាក់នៅក្នុងដៃទេនៅចុងការិយបរិច្ឆេទ។ អ្នកគ្រប់គ្រងមិនអាចផ្តល់ការធ្វៀងផ្ទាត់អ្វីដែលអាចពន្យល់ពីភាពខុសគ្នារវាងសាច់ប្រាក់ដែលបានកត់ត្រា និងសាច់ប្រាក់ក្នុងដៃនោះទេ។ នីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យយើងអនុវត្តនីតិវិធីសវនកម្មជំនួសទេ។ ហេតុដូច្នេះហើយ យើងមិនអាចធ្វៀងផ្ទាត់ភាពត្រឹមត្រូវនៃសមតុល្យសាច់ប្រាក់បានទេ ដែលអាចផលប៉ះពាល់ទៅលើធាតុផ្សេងទៀតនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022 ។

យើងខ្ញុំបានធ្វើសវនកម្មគណនេយ្យ ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកនៃ ***ការទទួលខុសត្រូវរបស់សវនករសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយអនុលោមតាមលក្ខខណ្ឌតម្រូវវិជ្ជាជីវៈដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវផ្សេងទៀតរបស់យើងខ្ញុំនៅក្នុងវិជ្ជាជីវៈស្របតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានភាពគ្រប់គ្រាន់ និងសមហេតុសមផល ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

របាយការណ៍របស់សវនករឯករាជ្យ
ជូនចំពោះភាគទុនិក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតមីថល ម.ក (តពីទំព័រមុន)

ពត៌មានផ្សេងទៀត

ថ្នាក់ដឹកនាំជាអ្នកទទួលខុសត្រូវចំពោះព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងទៀតដែលទទួលបាននៅកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ គឺជាព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដូចមានចែងនៅទំព័រទី 1 ដល់ទី 5 ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សវនករទេ។

មតិរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងទៀតទេ ហើយយើងខ្ញុំមិនធ្វើការសន្និដ្ឋានលើការធានាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងទៀតហើយធ្វើការពិចារណាថា តើព័ត៌មានផ្សេងទៀតមានលក្ខណៈមិនសមស្របជាសារវន្ត៍ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬបើមិនដូច្នោះទេ ថាតើវាទំនងជាមាននូវកំហុសឆ្គងជាសារវន្ត៍ដែរឬទេ។ ប្រសិនបើផ្អែកលើការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាមានព័ត៌មានខុសឆ្គងសំខាន់ៗនៃព័ត៌មានផ្សេងទៀតនេះ យើងខ្ញុំត្រូវរាយការណ៍អំពីករណីនេះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នោះទេ។

ការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ច លើរបាយការណ៍ហិរញ្ញវត្ថុ

ថ្នាក់ដឹកនាំជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុដោយយោងទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs) និងជាអ្នកទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដែលចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលគ្មានកំហុសឆ្គងជាសារវន្ត៍ (ដូចជាកំហុសឆ្គងដោយសារការក្លែងបន្លំ ឬ ការភាន់ច្រឡំ)។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ថ្នាក់ដឹកនាំទទួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម បង្ហាញតាមការពាក់ព័ន្ធនូវករណីដែលទាក់ទងទៅនឹងនិរន្តរភាពនៃដំណើរការអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មគណនេយ្យលើកលែងតែថ្នាក់ដឹកនាំមានបំណងដើម្បីជម្រះបញ្ជីក្រុមហ៊ុន ឬដើម្បីបញ្ឈប់ប្រតិបត្តិការអាជីវកម្ម ឬមិនមានជម្រើសណាផ្សេងពីនេះ។

ថ្នាក់ដឹកនាំផ្នែកអភិបាលកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

របាយការណ៍របស់សវនករឯករាជ្យ
ជូនចំពោះភាគទុនិក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេងណាខាត្រា យែតឌីថល ម.ក (តពីទំព័រមុន)

ការទទួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានការធានាដោយសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានកំហុសឆ្គងជាសារវន្ត (ដូចជាកំហុសឆ្គងដោយសារការក្លែងបន្លំ ឬ ការភាន់ច្រឡំ) និងដើម្បីចេញរបាយការណ៍សវនករមួយដែលរួមបញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំ។ ការធានាដោយសមហេតុផល គឺជាការធានាដែលមានកម្រិតខ្ពស់ ប៉ុន្តែមិនមែនជាការធានាមួយដែលថា សវនកម្មធ្វើឡើងស្របតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាតែងតែរកឃើញកំហុសឆ្គងជាសារវន្ត៍ណាមួយនៅពេលដែលវាកើតឡើងឡើយ។ កំហុសឆ្គងអាចកើតឡើងពីការបន្លំ ឬភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងមួយ ឬកំហុសឆ្គងជារួម ពួកវាអាចនឹងត្រូវបានគេរំពឹងដោយសមរម្យថា នឹងមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំធ្វើការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាមជ្ឈភាពនិយមវិជ្ជាជីវៈ នៅក្នុងការធ្វើសវនកម្ម។ យើងខ្ញុំក៏ៈ

ក) ធ្វើការកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ និងរៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិរបស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងសំខាន់ៗ ដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងកំហុសនៃការភាន់ច្រឡំ ដោយសារកំហុសឆ្គងនៃការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតការក្លែងបន្លំ ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការមិនធ្វើតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ខ) ទទួលបានការយល់ដឹងអំពីការត្រួតពិនិត្យផ្ទៃក្នុងទាក់ទងនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។

គ) ធ្វើការវាយតម្លៃភាពត្រឹមត្រូវនៃគោលនយោបាយគណនេយ្យដែលបានប្រើ និងភាពសមហេតុផលនៃការប៉ាន់ប្រមាណគណនេយ្យ ប្រសិនបើមាន និងការបង្ហាញពាក់ព័ន្ធដែលធ្វើឡើងដោយថ្នាក់ដឹកនាំ ។

ម៉ូរីសុនកាក់ អ៊ិមវ៉ូអេ
Morisonkak MKA
Audit-Accounting-Tax & Business Advisory

របាយការណ៍របស់សវនករឯករាជ្យ
ជូនចំពោះភាគទុនិក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតមីថល ម.ក (តពីទំព័រមុន)

ការឆ្លុះបញ្ចាំងរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ) ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគ្រឹះនិរន្តរភាពអាជីវកម្មនៃការចុះបញ្ជីគណនេយ្យរបស់ថ្នាក់ដឹកនាំ ដោយផ្អែកលើភស្តុតាងសវនកម្មដែលបានទទួល ថាតើភាពមិនប្រាកដប្រជាទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានការសង្ស័យយ៉ាងធ្ងន់ធ្ងរលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនប្រាកដប្រជា តម្រូវឲ្យយើងខ្ញុំទាញការចាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំចំពោះការបង្ហាញព័ត៌មានដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការបង្ហាញបែបនេះមិនគ្រប់គ្រាន់ ត្រូវធ្វើការកែប្រែមតិរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចបណ្តាលឱ្យក្រុមហ៊ុនតម្រូវឲ្យផ្អាកប្រតិបត្តិការអាជីវកម្ម ។

ង) ធ្វើការវាយតម្លៃលើការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មាន និងថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញប្រតិបត្តិការ និងព្រឹត្តិការណ៍សំខាន់ៗក្នុងលក្ខណៈដែលសម្រេចបាននូវការបង្ហាញដោយសមស្រប ។

យើងខ្ញុំបានទាក់ទងទៅអ្នកដែលទទួលបន្ទុកអភិបាលកិច្ចក្រុមហ៊ុនអំពីបញ្ហាផ្សេងៗ ដូចជាវិសាលភាព និង ពេលវេលាសវនកម្ម និងបញ្ហាសំខាន់ៗដែលរកឃើញក្នុងកំឡុងពេលសវនកម្ម រួមមានកង្វះខាតសំខាន់ៗនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ម៉ូរីសុនកាក់ អ៊ិមវ៉ូអេ
ក្រុមហ៊ុនគណនេយ្យជំនាញនិងសវនកម្មឯករាជ្យ

កាក់ ភី
ភាគទុនិកថ្នាក់ដឹកនាំ
ថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2023

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យ៉ែតមីថល ម.ក

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

				កំណត់ឡើងវិញ	
	កំណត់	31 ធ្នូ 2022		31 ធ្នូ 2021	
	សំគាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	4	30,423	125,251	-	-
សមតុល្យជាមួយធនាគារកណ្តាល		629	2,590	20	81
សមតុល្យជាមួយធនាគារនានា	5	67,593	278,280	102,255	416,587
ប្រាក់តម្កល់តាមច្បាប់ជាមួយធនាគារកណ្តាល	6	225,000	926,325	75,000	305,550
ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ	7	5,225,905	21,515,051	73,450	299,235
ទ្រព្យសកម្មផ្សេងទៀត	8	57,175	235,389	725,727	2,956,612
អចលនទ្រព្យ	9	93,450	384,734	125,746	512,289
ទ្រព្យសកម្មអរូបី	10	60,133	247,568	82,683	336,851
សរុបទ្រព្យសកម្ម		5,760,308	23,715,188	1,184,881	4,827,205
ទ្រព្យអកម្ម និង មូលធន					
ទ្រព្យអកម្ម					
បំណុលផ្សេងៗ	11	670,301	2,759,629	133,041	542,009
បំណុលដែលជំពាក់សម្ព័ន្ធភាគគី	12	1,333,334	5,489,336	-	-
ពន្ធសកម្មបច្ចុប្បន្ន	18	519	2,137	-	-
សរុបទ្រព្យអកម្ម		2,004,154	8,251,102	133,041	542,009

កំណត់សំគាល់ដែលមានភ្ជាប់ត្រូវអានជាមួយរបាយការណ៍នេះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាតាត្រា យែកឌីថល ម.ក

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

				កំណត់ឡើងវិញ	
		31 ធ្នូ 2022		31 ធ្នូ 2021	
	កំណត់សំគាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មូលធន					
ដើមទុន	12	4,500,000	18,526,500	1,500,000	6,111,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	13	52,245	212,846	738	3,007
ការខាតបង្គរ		(796,091)	(3,242,556)	(448,898)	(1,822,884)
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(32,704)	-	(5,927)
សរុបមូលធន		3,756,154	15,464,086	1,051,840	4,285,196
សរុបទ្រព្យអកម្មនិងមូលធន		5,760,308	23,715,188	1,184,881	4,827,205

អនុញ្ញាតអោយចេញផ្សព្វផ្សាយនិងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

លោក សេង សុខុម
ក្រុមប្រឹក្សាភិបាល
ថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2023

កំណត់សំគាល់ដែលមានភ្ជាប់ត្រូវអានជាមួយរបាយការណ៍នេះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាតាត្រា យែកឌីថល ម.ក

របាយការណ៍លទ្ធផលលម្អិត
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

		31 ធ្នូ 2022		31 ធ្នូ 2021	
	កំណត់សំគាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលពីការប្រាក់	14	255,110	1,043,145	1,103	4,487
ចំណូលពីការប្រាក់សុទ្ធ		**255,110**	**1,043,145**	**1,103**	**4,487**
ចំណូលកម្រៃសេវា និងកម្រៃភ្នាក់ងារ សុទ្ធ		1,383	5,655	-	-
ចំណូលផ្សេងៗ		716	2,928	2,149	8,742
ចំណូលពីប្រតិបត្តិការសរុប		**257,209**	**1,051,728**	**3,252**	**13,229**
ចំណាយផ្ទាល់ខ្លួន	15	(282,660)	(1,155,797)	(147,836)	(601,397)
រំលស់	8 & 9	(59,206)	(242,093)	(33,023)	(134,338)
ចំណាយលើប្រតិបត្តិការផ្សេងៗ	16	(208,457)	(852,381)	(141,251)	(574,609)
ចំណាយលើប្រតិបត្តិការសរុប		**(550,323)**	**(2,250,271)**	**(322,110)**	**(1,310,344)**
ប្រាក់ខាតមុនបង់ពន្ធ		**(293,114)**	**(1,198,543)**	**(318,858)**	**(1,297,115)**
ចំណាយពន្ធលើប្រាក់ចំណេញ	17	(2,572)	(10,517)	(21)	(85)
ប្រាក់ខាតសុទ្ធ		**(295,686)**	**(1,209,060)**	**(318,879)**	**(1,297,200)**
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(26,777)	-	(5,927)
ប្រាក់ខាតលម្អិតសុទ្ធ		**(295,686)**	**(1,235,837)**	**(318,879)**	**(1,303,127)**

អនុញ្ញាតអោយចេញផ្សព្វផ្សាយនិងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

លោក សេង សុខុម
ក្រុមប្រឹក្សាភិបាល
ថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2023

កំណត់សំគាល់ដែលមានភ្ជាប់ត្រូវអានជាមួយរបាយការណ៍នេះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេាង ណាវ៉ាត្រា យ៉ែរតីថល ម.ក

របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញកកុម្ភទុក/(ប្រាក់ខាតបង់)		លម្អៀងពីការប្តូរប្រាក់អាមេរិក		សរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល		ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទាំងថ្ងៃទី 1 ខែមេសា 2022	1,500,000	6,111,000	738	3,007	(448,898)	(1,822,884)	(5,927)		1,051,840	4,285,196
លទ្ធផលខាតសម្រាប់តាំយរយៈពេលមួយ	-	-	-	-	(295,686)	(1,209,060)	-		(295,686)	(1,209,060)
ការចេញមូលធនភាគហ៊ុន	3,000,000	12,351,000	-	-	-	-	-		3,000,000	12,351,000
ការកើនឡើងប្រាក់បម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	-	-	-		-	-
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	51,507	210,612	(51,507)	(210,612)	-		-	-
លម្អៀងពីការប្តូរប្រាក់យ៉ាងណា	-	64,500	-	(773)	-	-	(26,777)		-	36,950
ទាំងថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022	4,500,000	18,526,500	52,245	212,846	(796,091)	(3,242,556)	(32,704)		3,756,154	15,464,086
ទាំងថ្ងៃទី 1 ខែមេសា 2021	1,500,000	6,067,500	11,345	45,889	(140,626)	(568,831)	-		1,370,719	5,544,558
លទ្ធផលខាតសម្រាប់តាំយរយៈពេលមួយ	-	-	-	-	(318,879)	(1,297,200)	-		(318,879)	(1,297,200)
ការចេញមូលធនភាគហ៊ុន	-	-	-	-	-	-	-		-	-
ការកើនឡើងប្រាក់បម្រុងតាមបទប្បញ្ញត្តិ	-	-	(11,345)	(46,150)	11,345	46,150	-		-	-
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	738	3,003	(738)	(3,003)	-		-	-
លម្អៀងពីការប្តូរប្រាក់យ៉ាងណា	-	43,500	-	265	-	-	(5,927)		-	37,838
ទាំងថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2021	1,500,000	6,111,000	738	3,007	(448,898)	(1,822,884)	(5,927)		1,051,840	4,285,196

កំណត់សំគាល់ដែលមានភ្ជាប់ត្រូវអានជាមួយរបាយការណ៍នេះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេាង ណាវ៉ាត្រា យ៉ែរតីថល ម.ក

របាយការណ៍លំហូរសាច់ប្រាក់
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

	31 ធ្នូ 2022		31 ធ្នូ 2021 (កំណត់ឡើងវិញ*)	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចរន្តសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ខាត មុនបង់ពន្ធ	(293,114)	(1,198,543)	(318,858)	(1,297,115)
និយ័តកម្មចំពោះ ៖				
ចំណូលពីការប្រាក់សុទ្ធ	(255,110)	(1,043,145)	(1,103)	(4,487)
ការខាតបង់លើការថយចុះតម្លៃនៃឥណទានផ្តល់ដល់អតិថិជន	-	-	-	-
រំលស់ទ្រព្យសកម្ម និងរំលស់ទ្រព្យអសកម្ម	59,206	242,093	33,023	134,338
ខាតបង់ទ្រព្យ និងបរិក្ខារ	-	-	1,867	7,595
ការខាតប្រតិបត្តិការមុនពេលផ្លាស់ប្តូរដើមទុន	(489,018)	(1,999,595)	(285,071)	(1,159,669)
បម្រែបម្រួលដើមទុន				
ឥណទានផ្តល់ដល់អតិថិជន	(5,115,842)	(20,918,678)	13,421	54,597
ទ្រព្យសកម្មផ្សេងៗ	668,552	2,733,709	(724,108)	(2,945,671)
បំណុលផ្សេងៗ	537,260	2,196,856	125,179	509,228
បំណុលដែលជំពាក់ភាគីពាក់ព័ន្ធ	1,333,334	5,452,003	-	-
សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ	(3,065,714)	(12,535,705)	(870,579)	(3,541,515)
ការប្រាក់ដែលបានទទួល*	218,497	893,434	725	2,949
ការប្រាក់បានបង់	(2,053)	(8,395)	(30)	(122)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ	(2,849,270)	(11,650,666)	(869,884)	(3,538,688)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ				
ប្រាក់បញ្ញើតាមច្បាប់	(150,000)	(613,350)	-	-
ការទិញទ្រព្យ និងបរិក្ខារ	(4,360)	(17,828)	(150,942)	(614,032)
ការទិញទ្រព្យអរូបី	-	-	(90,200)	(366,934)
សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពវិនិយោគ	(154,360)	(631,178)	(241,142)	(980,966)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ				
ការចេញមូលធនភាគហ៊ុន	3,000,000	12,267,000	-	-
សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពហិរញ្ញវត្ថុ	3,000,000	12,267,000	-	-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីថល ម.ក

របាយការណ៍លំហូរសាច់ប្រាក់
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

			កំណត់ឡើងវិញ *	
	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក	ពាន់រៀល
បម្រែបម្រួលសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល	(3,630)	(14,844)	(1,111,026)	(4,519,654)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ	102,275	416,668	1,213,301	4,907,802
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	4,297	-	28,520
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ	98,645	406,121	102,275	416,668
បង្ហាញដោយ៖				
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	30,423	125,251	-	-
សមតុល្យជាមួយធនាគារកណ្តាល	629	2,590	20	81
សមតុល្យជាមួយធនាគារនានា	67,593	278,280	102,255	416,587
	98,645	406,121	102,275	416,668

កំណត់សំគាល់ដែលមានភ្ជាប់ត្រូវអានជាមួយរបាយការណ៍នេះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីថល ម.ក

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

1. លក្ខណៈទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីថល ម.ក (លំដាប់នេះតទៅហៅកាត់ថា "ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការចុះបញ្ជីពាណិជ្ជកម្មថ្មីលេខ ០០០២៧៩១៦ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ ចេញដោយក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណម្តងទៀតពី ធនាគាជាតិនៃកម្ពុជា នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២១ ក្រោមឈ្មោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវាត្រា យៃតីថល ម.ក។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ក្នុងការបើកដំណើរការអាជីវកម្មជាស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ ។ ផ្អែកលើអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុនមានសិទ្ធិក្នុងការផ្តល់ឥណទានដល់ប្រជាជនទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងកន្លែងអាជីវកម្មរបស់ក្រុមហ៊ុន មានទីតាំងនៅផ្លូវ OCIC ភូមិ គៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនមានបុគ្គលិកសរុប ២៩ នាក់ នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតអោយចេញផ្សព្វផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2023។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ

គោលការណ៍គណនេយ្យជាចំបងត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានគេអនុវត្តដូចៗគ្នាចំពោះគ្រប់ការិយបរិច្ឆេទទាំងអស់ ដែលបានបង្ហាញលើកលែងតែមានលក្ខខណ្ឌតម្រូវណាមួយចែងផ្ទុយពីនេះ។

2.1 មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (ហៅកាត់ថា "CIFRS for SMEs") ដែលផ្អែកលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម ទាំងស្រុង ដែលចេញផ្សាយដោយ ក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិ និងទទួលស្គាល់ដោយក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងតាមសម្មតិកម្មតម្លៃដើម និងបង្ហាញជាប្រាក់ដុល្លារអាមេរិក។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.1 មូលដ្ឋានៃការរៀបចំ (តពីទំព័រមុន)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS for SMEs តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ និងការសន្មត់ ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួនទឹកប្រាក់ចំណូល និងចំណាយដែលបានរាយការណ៍ នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ ហើយក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យនៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យទាំងនេះ ផ្អែកទៅលើកម្រិតនៃការយល់ដឹងរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។

2.2 ការប្តូររូបិយប័ណ្ណ

ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

ធាតុទាំងអស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានគេវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃសេដ្ឋកិច្ចជាចំបង ដែលក្រុមហ៊ុនប្រតិបត្តិ ("រូបិយប័ណ្ណគោល")។ ក្រុមហ៊ុនមានប្រតិបត្តិការភាគច្រើនជាប្រាក់ដុល្លារអាមេរិក និងធ្វើការកត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណដែលត្រូវបង្ហាញ ពីព្រោះរូបិយប័ណ្ណនេះឆ្លុះបញ្ចាំងភាពជាក់ស្តែងនៃសកម្មភាពសេដ្ឋកិច្ចទៅតាមប្រតិបត្តិការ និង កាលៈទេសៈរបស់ក្រុមហ៊ុន ។

ខ. ប្រតិបត្តិការ និងសមតុល្យ

រាល់ប្រតិបត្តិការចំណូល-ចំណាយជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់ដុល្លារអាមេរិកត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារ ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ ។ ភាពខុសគ្នានៃអត្រាប្តូរប្រាក់ចំពោះប្រតិបត្តិការ និងការបកប្រែទៅអត្រាប្តូរប្រាក់នៅដំណាច់ការិយបរិច្ឆេទចំពោះសមតុល្យទ្រព្យសកម្ម និងអកម្មជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់ដុល្លាអាមេរិកត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.3 ការបញ្ជាញជាប្រាក់រៀល

អនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម តម្រូវឱ្យបកប្រែរបាយការណ៍ហិរញ្ញវត្ថុពីដុល្លារអាមេរិកទៅជាប្រាក់រៀល។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់តម្រូវឱ្យមានការបកប្រែទៅជាប្រាក់រៀលដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគ។ ភាពខុសគ្នានៃអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងគណនីលទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើអត្រាប្តូរប្រាក់ជាផ្លូវការដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជាដូចខាងក្រោម ៖

ការិយបរិច្ឆេទនៃរបាយការណ៍	អត្រាប្តូរប្រាក់ចុងឆ្នាំ	អត្រាប្តូរប្រាក់មធ្យមភាគ
31 ខែ ធ្នូ ឆ្នាំ 2022	1 ដុល្លារអាមេរិក = 4,117 រៀល	1 ដុល្លារអាមេរិក = 4,089 រៀល

2.4 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(i). ការកត់ត្រា និងការវាស់វែងលើកដំបូង

ក្រុមហ៊ុនទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនក្លាយជាភាគីនៃកិច្ចសន្យា។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានកត់ត្រាលើកដំបូងតាមតម្លៃប្រតិបត្តិការ រួមបញ្ចូលទាំងចំណាយប្រតិបត្តិការ។

(ii). ចំណាត់ថ្នាក់ និងការវាស់វែងពេលបន្ទាប់

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានចាត់ថ្នាក់ជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន រួមមាន សាច់ប្រាក់ និង ឧបករណ៍បំណុល (ប្រាក់បញ្ញើ និងប្រាក់បញ្ញើនៅធនាគារនានា ប្រាក់កម្ចី ទឹកប្រាក់ត្រូវទទួលផ្សេងៗ និងទឹកប្រាក់ត្រូវសងផ្សេងៗ)។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានវាស់វែងនាពេលបន្ទាប់តាមថ្លៃដើមដកតម្លៃសល់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ដកសំវិធានធនការថយចុះនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការធ្វើអប្បហារនឹងមិនត្រូវបានប្រសិនបើការធ្វើអប្បហារមិនមានផលប៉ះពាល់ជាសារវន្ត។

2. **គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ** (តពីទំព័រមុន)

2.4 **ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ**

*(iii). **ការឈប់កត់ត្រា***

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់កត់ត្រា នៅពេលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះបានបញ្ឈប់ ឬទ្រព្យសកម្មត្រូវបានផ្ទេរ និងរាល់ហានិភ័យ និងផលប្រយោជន៍កម្មសិទ្ធទាំងអស់នៃទ្រព្យសកម្មត្រូវបានផ្ទេរ។ ភាពខុសគ្នារវាងតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងតម្លៃតបស្នងដែលបានទទួល និងត្រូវទទួលសរុបត្រូវបានកត់ត្រាជាចំណេញរឺខាត។

បំណុលហិរញ្ញវត្ថុត្រូវបានឈប់កត់ត្រាតែនៅពេលដែលកាតព្វកិច្ចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុ និងតម្លៃតបស្នងដែលត្រូវបានទូទាត់ រឺជំពាក់ រាប់បញ្ចូលទាំងការផ្ទេរទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ រឺបំណុលដែលបានសន្មត់ ត្រូវបានកត់ត្រាជាចំណេញរឺខាត។

*(iv). **ការកាត់កង***

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានកត់ត្រា ហើយក្រុមហ៊ុនមានបំណងនឹងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ ទឹកប្រាក់ដែលពាក់ព័ន្ធត្រូវបានបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

2.5 **ការថយចុះនៃតម្លៃរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ**

*(i). **ការថយចុះនៃទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់***

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានការថយចុះតម្លៃ ប្រសិនបើមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ ដែលជាលទ្ធផលបណ្តាលមកពីព្រឹត្តិការណ៍មួយ ឬច្រើន ដែលបានកើតឡើងបន្ទាប់ពីការកត់ត្រាទ្រព្យសកម្មលើកដំបូង ("ព្រឹត្តិការណ៍ខាតបង់" ដែលបានកើតឡើង) ហើយព្រឹត្តិការណ៍ខាតបង់ (ឬព្រឹត្តិការណ៍)នោះ មានផលប៉ះពាល់ចំពោះលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអាចប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

2. **គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ** (តពីទំព័រមុន)

2.5 **ការថយចុះនៃតម្លៃរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ** (តពីទំព័រមុន)

*(i). **ការថយចុះនៃទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់*** (តពីទំព័រមុន)

លក្ខណៈវិនិច្ឆ័យដែលក្រុមហ៊ុនបានប្រើប្រាស់ដើម្បីកំណត់អំពីភ័ស្តុតាង ដែលបញ្ជាក់ពីការខាតបង់បណ្តាលមកពីការថយចុះតម្លៃរួមមាន សញ្ញាបង្ហាញថាអ្នកខ្ចីប្រាក់ ឬក្រុមអ្នកខ្ចីប្រាក់កំពុងជួបប្រទះនឹងផលវិបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង លទ្ធភាពដែលពួកគេនឹងត្រូវក្ស័យធន ឬការកែសម្រួលហិរញ្ញវត្ថុផ្សេងៗឡើងវិញ ការខកខានមិនបានបង់ការប្រាក់ និងប្រាក់ដើម និងនៅពេលដែលទិន្នន័យដែលអាចអង្កេតបានចង្អុលបង្ហាញថា មានការថយចុះដែលអាចវាស់វែងបាននៅក្នុងលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដូចជាបម្រែបម្រួលនៃការខកខានលើការសងប្រាក់ ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានក្នុងការសងប្រាក់។ ក្រុមហ៊ុនបានកំណត់ជាដំបូងអំពីភ័ស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃក្នុងលក្ខណៈដាច់ដោយឡែកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុទំហំធំ និងកំណត់លក្ខណៈដាច់ដោយឡែក ឬជារួមចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានទំហំតូច។ ប្រសិនបើក្រុមហ៊ុនកំណត់ថាមិនមានភ័ស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុបានកំណត់លក្ខណៈដាច់ដោយឡែក ទោះបីមានទំហំធំ ឬតូចក៏ដោយ វាក៏ត្រូវបានរាប់បញ្ចូលក្នុងក្រុមទ្រព្យសកម្ម នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា និងបានកំណត់ជារួមចំពោះការថយចុះតម្លៃ។

ចំនួនទឹកប្រាក់នៃការខាតបង់ត្រូវបានវាស់វែងទៅតាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្នដែលបានប៉ាន់ស្មានការធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត តាមអត្រាការប្រាក់មានប្រសិទ្ធភាពដំបូងរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ តម្លៃយោងនៃទ្រព្យសកម្ម ត្រូវបានកាត់បន្ថយតាមរយៈការប្រើគណនីសំវិធានធន ហើយចំនួនទឹកប្រាក់ខាតបង់ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលលម្អិត។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុមានអត្រាការប្រាក់អថេរ នោះអត្រាអប្បហារសម្រាប់ការវាស់វែងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ គឺជាអត្រាការប្រាក់មានប្រសិទ្ធភាព ដែលត្រូវបានកំណត់ក្នុងកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនត្រូវបានវាយតម្លៃដាច់ដោយឡែក ត្រូវបានដាក់ជាក្រុមរួមគ្នា ដើម្បីធ្វើការកំណត់រក portfolio នៃការថយចុះតម្លៃ។ ឥណទានត្រូវបានដាក់ជាក្រុម ដោយយោងទៅតាមលក្ខណៈហានិភ័យឥណទានរបស់វា ដើម្បីធ្វើការគណនាប៉ាន់ស្មានការខាតបង់ជារួម។ លក្ខណៈទាំងនេះមានទំនាក់ទំនងជាមួយនឹងការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត សម្រាប់ក្រុមនៃទ្រព្យសកម្មតាមរយៈការចង្អុលបង្ហាញពីសមត្ថភាពរបស់កូនបំណុល ក្នុងការសងប្រាក់គ្រប់ចំនួន ដោយយោងទៅតាមលក្ខខណ្ឌក្នុងកិច្ចសន្យា នៃទ្រព្យសកម្មដែលត្រូវបានវាយតម្លៃ។ លំហូរសាច់ប្រាក់នាពេលអនាគតចំពោះក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកំណត់រកការថយចុះតម្លៃជារួម ត្រូវបានប៉ាន់ស្មានដោយផ្អែកទៅលើមូលដ្ឋានបទពិសោធន៍ខាតបង់មុនៗចំពោះទ្រព្យសកម្មដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងនឹងទ្រព្យសកម្មក្នុងក្រុម។

2. **គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ** (ពីទំព័រមុន)

2.5 **ការថយចុះនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ** (ពីទំព័រមុន)

(i). ការថយចុះនៃទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់(ពីទំព័រមុន)

វិធីសាស្ត្រ និងការសន្មត់ ដែលត្រូវបានប្រើប្រាស់សម្រាប់ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដោយក្រុមហ៊ុន ដើម្បីកាត់បន្ថយភាពខុសគ្នារវាងការប៉ាន់ស្មានការខាតបង់នានា និងបទពិសោធន៍ការខាតបង់ជាក់ស្តែង។ពេលឥណទានមិនអាចប្រមូលមកវិញបាន វាត្រូវបានជម្រះចេញពីបញ្ជីដោយកាត់កងពីគណនីសំវិធានធនសម្រាប់ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ។ ឥណទានប្រភេទនេះត្រូវបានជម្រះចេញពីបញ្ជីក្រុមហ៊ុន បន្ទាប់ពីបានពិចារណាពីតម្លៃជាក់ស្តែងនៃវត្ថុបញ្ចាំ ប្រសិនបើមាន នៅពេលដែលគណៈគ្រប់គ្រងបានវិនិច្ឆ័យថា ក្រុមហ៊ុនមិនមានលទ្ធភាពប្រមូលប្រាក់នោះមកវិញបាន។

ក្នុងការិយបរិច្ឆេទបន្ទាប់ ប្រសិនបើមានតំហយក្នុងចំនួនទឹកប្រាក់ខាតបង់បណ្តាលមកពីការថយចុះតម្លៃ ហើយតំហយនោះអាចនឹងទាក់ទងនឹងព្រឹត្តិការណ៍ជាក់ស្តែងមួយដែលបានកើតឡើង បន្ទាប់ពីការកត់ត្រាការថយចុះតម្លៃ (ដូចជាការប្រសើរឡើងនៃអត្រាឥណទានរបស់កូនបំណុល) នោះការខាតបង់បណ្តាលមកពីការថយចុះតម្លៃដែលត្រូវបានកត់ត្រាក្នុងគ្រាមុន ត្រូវបានកត់ត្រាត្រឡប់ទៅវិញ ដោយការធ្វើនិយ័តកម្មលើគណនីសំវិធានធន។ ចំនួនទឹកប្រាក់ដែលប្រមូលបានមកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

(ii). ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វានៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វានឹងមិនអាចស្រង់មកវិញបាន។ ប្រសិនបើមានការចង្អុលបង្ហាញថាថយចុះតម្លៃ តម្លៃដែលអាចស្រង់មកវិញបាននៃទ្រព្យណាដែលរងការប៉ះពាល់ត្រូវបានប៉ាន់ស្មាន និងធៀបជាមួយតម្លៃយោងរបស់វា។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រាភ្លាមៗតាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។

ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។ ការកត់ត្រាការខាតបង់បណ្តាលមកពីការថយចុះតម្លៃត្រលប់មកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត ទៅតាមតម្លៃយោងរបស់ទ្រព្យសកម្ម ដែលមិនលើសពីតម្លៃយោងដែលបានកំណត់ កាត់កងជាមួយនឹងរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី ប្រសិនបើមិនបានកត់ត្រាការខាតបង់បណ្តាលមកពីការថយចុះតម្លៃ។

2. **គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ** (ពីទំព័រមុន)

2.6 **សាច់ប្រាក់ និង សាច់ប្រាក់សមមូល**

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យមិនមានកំហិតនៅធនាគារជាតិនៃកម្ពុជា និងសមតុល្យនៅធនាគារនានា ដែលងាយស្រួលបំលែងជាសាច់ប្រាក់បានក្នុងរយៈពេលកំណត់ពិចជាងរយៈពេលបីខែ ហើយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរនៃតម្លៃរបស់វា។

2.7 **ប្រាក់តំកល់ដើមទុននៅធនាគារកណ្តាល**

ប្រាក់តំកល់តាមច្បាប់ រួមមានមូលនិធិបំរុង និងប្រាក់តំកល់នៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ប្រាក់តំកល់តាមច្បាប់មិនអាចយកមកប្រើប្រាស់សំរាប់ប្រតិបត្តិការប្រចាំថ្ងៃទេ ហើយពុំត្រូវបានចាត់ទុកជាចំណែកនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងការគណនារបាយការណ៍លំហូរសាច់ប្រាក់។

2.8 **ឥណទានផ្តល់ដល់អតិថិជន**

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ធ ដែលការទូទាត់ប្រាក់មានលក្ខណៈថេរ ឬអាចកំណត់បានដែលមិនត្រូវបានដកស្រង់នៅលើទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗឬក្នុងរយៈពេលខ្លីនោះទេ។

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូកការចំណាយប្រតិបត្តិការដោយផ្ទាល់បន្ថែម ហើយត្រូវបានវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

2.9 **ទ្រព្យសកម្មផ្សេងទៀត**

ទ្រព្យសកម្មផ្សេងទៀតត្រូវបានទទួលស្គាល់ដំបូងក្នុងតម្លៃប្រតិបត្តិការ ហើយវាស់វែងជាបន្តបន្ទាប់ក្នុងតម្លៃរំលោះដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព លុះត្រាតែអប្បហារមិនមានផលប៉ះពាល់ជាសារវន្ត ក្នុងករណីដែលត្រូវបានបញ្ជាក់ក្នុងតម្លៃប្រតិបត្តិការ។

2.10 **អចលនទ្រព្យ និងបរិក្ខារ**

អចលនទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើមដោយដកបន្ថយនូវរំលស់បង្គរ និងការខាតបង់ដោយសារការចុះនៃតម្លៃ ។ តម្លៃដើមរាប់បញ្ចូលចំណាយផ្សេងៗ ដែលទាក់ទងផ្ទាល់នឹងការទិញអចលនទ្រព្យ។ តាមករណីជាក់ស្តែងថ្លៃដើមបន្តបន្ទាប់ត្រូវបានបញ្ចូលទៅក្នុងតម្លៃយោង ឬទទួលស្គាល់ជាទ្រព្យសកម្មមួយផ្សេងទៀត តែនៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ចទៅអនាគត ដែលពាក់ព័ន្ធជាមួយទ្រព្យនោះនឹងហូរចូលមកក្រុមហ៊ុន ហើយថ្លៃដើមនៃធាតុនោះអាចត្រូវបានវាស់វែងដោយជឿទុកចិត្តបាន។ រាល់ការជួសជុល និងការថែទាំត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលលម្អិតនៅក្នុងការិយបរិច្ឆេទ ដែលការជួសជុល និងថែទាំនោះបានកើតឡើង។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.10 អចលនទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

ការដកវិលស់លើអចលនទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងចំណេញឬខាត តាមមូលដ្ឋានវិលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃអចលនទ្រព្យនីមួយៗនោះ តាមអត្រាដូចខាងក្រោម៖

	អាយុកាលប្រើប្រាស់
ការកែលម្អទ្រព្យជួល	4 ឆ្នាំ
គ្រឿងសង្ហារិម និងបរិក្ខារ	4 ឆ្នាំ
បរិក្ខារការិយាល័យ	4 ឆ្នាំ
បរិក្ខារព័ត៌មានវិទ្យា	4 ឆ្នាំ

តម្លៃយោងរបស់អចលនទ្រព្យ ត្រូវបានកាត់បន្ថយភ្លាមមកត្រឹមតម្លៃអាចស្រង់មកវិញបានរបស់វា ប្រសិនបើតម្លៃ យោងមានចំនួនធំជាងតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន ។ តម្លៃអាចស្រង់មកវិញបាន គឺជាតម្លៃខ្ពស់ ជាងគេរវាងតម្លៃសមស្របដកចេញសោហ៊ុយលក់ ធៀបនឹងតម្លៃប្រើប្រាស់របស់វា។

ធាតុនៃអចលនទ្រព្យនីមួយៗ ត្រូវបានឈប់ទទួលស្គាល់ នៅពេលមានការលក់/ដកចេញ ឬនៅពេលពុំមានអត្ថប្រយោជន៍សេដ្ឋកិច្ចទៅអនាគតត្រូវបានរំពឹងទុកពីការប្រើប្រាស់របស់វា ឬការលក់/ដកចេញរបស់វា។ ចំណេញ និងខាតត្រូវបានកំណត់ឡើង ដោយប្រៀបធៀបទឹកប្រាក់ទទួលបាន ជាមួយតម្លៃយោងនៅសល់ក្នុងគណនេយ្យ និងត្រូវបានកត់ត្រាក្នុងចំណេញឬខាត ។

2.11 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានប្រព័ន្ធធនាគារស្នូលដែលរួមបញ្ចូលទាំងថ្លៃដើមក្នុងការទិញ និងដំឡើងសូហ្វវែរដែលមិនមែនជាផ្នែកដែលភ្ជាប់នឹងប្រតិបត្តិនៃហាដវែរ ហើយត្រូវបានកត់ត្រាតាមតម្លៃដើម ដកវិលស់បង្គរ និងការខាតបង់ការថយចុះនៃតម្លៃបង្គរ ប្រសិបបើមាន។ ថ្លៃដើមសូហ្វវែរ ត្រូវបានដកវិលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ ៤ ឆ្នាំ តាមវិធីសាស្ត្រវិលស់ថេរ។

ថ្លៃដើមពាក់ព័ន្ធនឹងសំណើរបង្កើត ឬវាយតម្លៃសំណើរបង្កើតសូហ្វវែរ ឬថែទាំកុំព្យូទ័រសូហ្វវែរបន្ទាប់ពីប្រើប្រាស់ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

2.12 សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.12 សំវិធានធន (តពីទំព័រមុន)

សំវិធានធនត្រូវបានគណនាតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

2.13 បំណុលផ្សេងៗ

បំណុលផ្សេងទៀតត្រូវបានទទួលស្គាល់តាមតម្លៃប្រតិបត្តិការ ហើយត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃរំលោះ លុះត្រាតែអប្បហារមិនមានផលប៉ះពាល់ជាសារវន្ត ក្នុងករណីដែលត្រូវបានបញ្ជាក់ក្នុងតម្លៃប្រតិបត្តិការ។

2.14 ចំណូលការប្រាក់

ចំណូលការប្រាក់ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់ទាំងអស់ត្រូវបានវាស់វែងតាមរលស់ថ្លៃដើមបានកត់ត្រាក្នុង "ចំណូលការប្រាក់" និង "ចំណាយការប្រាក់" ក្នុងរបាយការណ៍លទ្ធផលលម្អិត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រក្នុងការគណនារំលស់ថ្លៃដើម នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយឬបំណុលហិរញ្ញវត្ថុមួយ និងជាវិធីសាស្ត្រក្នុងការបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់លើរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់មានប្រសិទ្ធភាពគឺជាអត្រាដែលធ្វើអប្បហារជាក់ស្តែងចំពោះការទូទាត់ ឬការទទួលប្រាក់សាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយដែលខ្លីជាងទៅតាមការសមស្របលើតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាព ក្រុមហ៊ុនបានរួមបញ្ចូលរាល់លក្ខខណ្ឌក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬចំណាយបន្ថែមនានា ដែលបានចំណាយផ្ទាល់លើឧបករណ៍នោះ ហើយវាជាផ្នែកមួយនៃអត្រាការប្រាក់មានប្រសិទ្ធភាព ប៉ុន្តែមិនមែនជាការខាតឥណទាននាពេលអនាគតទេ។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (ឥតពីទំព័រមុន)

2.14 ចំណូលការប្រាក់(ឥតពីទំព័រមុន)

នៅពេលមានការប្រែប្រួលចំពោះការទូទាត់ ឬ ការទទួលសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត នោះតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណូលហិរញ្ញវត្ថុត្រូវបានកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងលំហូរសាច់ប្រាក់ប៉ាន់ស្មានជាក់ស្តែង និង លំហូរសាច់ប្រាក់ប៉ាន់ស្មានដែលបានកែតម្រូវ។ តម្លៃយោងត្រូវបានគណនាឡើងវិញ ដោយគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត តាមអត្រាការប្រាក់ដើមមានប្រសិទ្ធភាពរបស់
ឧបករណ៍ហិរញ្ញវត្ថុ។ និយ័តកម្មនេះត្រូវបានកត់ត្រាជាចំណូលការប្រាក់ ឬចំណាយការប្រាក់នៅក្នុងរបាយការណ៍លទ្ធផលលម្អិត នាកាលបរិច្ឆេទការកែតម្រូវ។

ការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលថយចុះតម្លៃត្រូវបានកត់ត្រាដោយប្រើប្រាស់អត្រាការប្រាក់ដែលត្រូវបានប្រើដើម្បីធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតសម្រាប់វាស់វែងការខាតបង់បណ្តាលមកពីការថយចុះតម្លៃ។

នៅពេលទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ ក្រុមហ៊ុនកាត់បន្ថយតម្លៃយោងឱ្យនៅត្រឹមចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន ដែលជាលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ធ្វើអប្បហារតាមអត្រាការប្រាក់ដើមមានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុ និងបន្តកត់ត្រាបង្គរឡើងវិញនូវតម្លៃអប្បហាររួចជាចំណូលការប្រាក់។ ចំណូលការប្រាក់ចំពោះភតិសន្យាត្រូវទទួលដែលមានការថយចុះតម្លៃ ត្រូវបានកត់ត្រាដោយប្រើអត្រាការប្រាក់ដើមមានប្រសិទ្ធភាព។

2.15. ចំណូល និង ចំណាយកម្រៃសេវា និងកម្រៃភ្នាក់ងារ

ចំណូលកម្រៃសេវា និងកម្រៃភ្នាក់ងារ រួមមានថ្លៃដំណើរការប្រាក់កម្ចី ថ្លៃពិន័យសម្រាប់ការបង់ប្រាក់យឺត និងការផាកពិន័យសម្រាប់ការបង់មុន។

ចំណូលកម្រៃសេវា និងកម្រៃភ្នាក់ងារផ្សេងៗមិនរួមបញ្ចូលការប្រាក់ប្រសិទ្ធភាពនៃប្រាក់កម្ចីក្នុងការចំណាយរំលោះទេ ដូច្នេះហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណូលនៅពេលផ្តល់សេវាកម្ម។ ថ្លៃសេវាផ្សេងទៀតលើការផាកពិន័យដែលគិតសម្រាប់ការបង់ប្រាក់យឺត និងការផាកពិន័យលើការបង់ប្រាក់មុនត្រូវបានទទួលស្គាល់នៅពេលដែលសាច់ប្រាក់ត្រូវបានទទួល។

ចំណាយកម្រៃសេវា និងកម្រៃភ្នាក់ងារផ្សេងទៀតត្រូវបានទទួលស្គាល់លើមូលដ្ឋានបង្គរ ដោយសារសេវាត្រូវបានទទួល។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (ឥតពីទំព័រមុន)

2.16. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញសំរាប់ការិយបរិច្ឆេទ រួមមានពន្ធលើប្រាក់ចំណេញនៃការិយបរិច្ឆេទ និងពន្ធពន្យា។ ចំណាយពន្ធត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទ។ ពន្ធក្រៅពីពន្ធលើប្រាក់ចំណេញត្រូវបានកត់ត្រាជាចំណាយប្រតិបត្តិការ។

ពន្ធលើប្រាក់ចំណេញនៃការិយបរិច្ឆេទ គឺជាពន្ធដែលត្រូវបានគណនាតាមមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធ ដោយគណនាតាមអត្រាពន្ធជាធរមាន ឬអត្រាពន្ធដែលគិតថាជាធរមាននៅថ្ងៃរាយការណ៍ ដោយអនុលោមទៅតាមច្បាប់សារពើពន្ធ។

ពន្ធពន្យាត្រូវបានគណនាទៅលើភាពលំអៀងជាបណ្តោះអាសន្នរវាងមូលដ្ឋានគិតពន្ធនៃតម្លៃយោងនៃទ្រព្យសកម្ម និងអកម្ម ធៀបនឹងតំលៃយោងដែលបានរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ តម្លៃដែលបានកំណត់ចំពោះពន្ធពន្យា មានមូលដ្ឋានលើការព្យាករណ៍លើការសំរេចបាន ឬការទូទាត់នៃតម្លៃយោងនៃទ្រព្យសកម្ម និងអកម្ម ដោយប្រើអត្រាពន្ធដែលបានកំណត់នៅថ្ងៃរបាយការណ៍។

ពន្ធពន្យាសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីដែលរំពឹងថា នឹងមានលទ្ធផលចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីកាត់កងជាមួយពន្ធពន្យាសកម្មនោះ។ ពន្ធពន្យាសកម្ម ត្រូវបានកាត់បន្ថយក្នុងករណីដែលលែងមានការរំពឹងថាអត្ថប្រយោជន៍ពន្ធនោះអាចនឹងប្រើប្រាស់បានទៀត ។

ពន្ធពន្យាសកម្ម និងអកម្មត្រូវបានកាត់កងនៅពេលដែលមានសិទ្ធិអនុវត្តតាមច្បាប់ ដើម្បីកាត់កងពន្ធសកម្មចរន្ត ជាមួយនឹងបំណុលពន្ធចរន្ត និងនៅពេលដែលវាទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលប្រមូលដោយអាជ្ញាធរពន្ធដារដូចគ្នា ហើយក្រុមហ៊ុនមានបំណងកាត់កងពន្ធសកម្មចរន្ត និងបំណុលពន្ធតាមមូលដ្ឋានសុទ្ធ ។

2.17 ភតិសន្យាប្រតិបត្តិ

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងទទួលបានផលកម្មសិទ្ធិលើទ្រព្យនោះត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលលម្អិតតាមមូលដ្ឋានថេរអាស្រ័យទៅតាមរយៈពេលនៃភតិសន្យានោះ។

2.18 ដើមទុន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាភាគហ៊ុន។ ភាគហ៊ុនផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាភាគហ៊ុន និង/ឬបំណុល យោងទៅតាមខ្លឹមសារសេដ្ឋកិច្ចនៃឧបករណ៍ពិសេស។ ការចែកចាយទៅឱ្យអ្នកកាន់ឧបករណ៍ហិរញ្ញវត្ថុដែលចាត់ថ្នាក់ជាឧបករណ៍មូលធនត្រូវបានគិតប្រាក់ទៅក្នុងសមធម៌។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (ត្រូវបន្ត)

2.19 ទុនបម្រុងតាមបទប្បញ្ញត្តិ

អនុលោមទៅតាមប្រកាសលេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី01 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមកែរមិន" ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យគណនាសំវិធានធនតាមបទប្បញ្ញត្តិសំរាប់ឧបករណ៍ហិរញ្ញវត្ថុទាំងអស់ ហើយសំវិធានធនតាមបទប្បញ្ញត្តិអ្ឃ្ឃបរមាត្រូវធ្វើឡើងយោងទៅតាមចំណាត់ថ្នាក់នោះ។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទានផ្តល់ដល់អតិថិជនត្រូវធ្វើចំណាត់ថ្នាក់តាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖

ចំណាត់ថ្នាក់	**ចំនួនថ្ងៃដែលហួសកាលកំណត់សង**	**អត្រាសំវិធានធន**
ឥណទានរយៈពេលខ្លី(តិចជាង ឬស្មើមួយឆ្នាំ)៖		
ឥណទានធម្មតា/ស្តង់ដា	<15 ថ្ងៃ	1%
ឥណទានឃ្លាំមើល	15 days – 30 ថ្ងៃ	3%
ឥណទានក្រោមស្តង់ដារ	31 days – 60 ថ្ងៃ	20%
ឥណទានជាប់សង្ស័យ	61 days – 90 ថ្ងៃ	50%
ឥណទានបាត់បង់	≥ 91 ថ្ងៃ	100%
ឥណទានរយៈពេលវែង(ច្រើនជាងមួយឆ្នាំ)៖		
ឥណទានធម្មតា/ស្តង់ដា	<30 ថ្ងៃ	1%
ឥណទានឃ្លាំមើល	≥ 30 ថ្ងៃ – 89 ថ្ងៃ	3%
ឥណទានក្រោមស្តង់ដារ	≥ 90 ថ្ងៃ – 179 ថ្ងៃ	20%
ឥណទានជាប់សង្ស័យ	≥ 180 ថ្ងៃ – 359 ថ្ងៃ	50%
ឥណទានបាត់បង់	359 ថ្ងៃ ឬច្រើនជាងនេះ	100%

ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនខ្ពស់ជាងការថយចុះតម្លៃបង្គរផ្អែកតាម CIFRS for SMEs នោះ 'ការបំពេញបន្ថែម - topping up' នឹងត្រូវបានកត់ត្រាជាទុនបម្រុងតាមច្បាប់ និងត្រូវបានដាក់បង្ហាញនៅក្នុងមូលធន។ បន្ទាប់មក ទុនបម្រុងត្រូវបានកត់ត្រាត្រឡប់ទៅវិញ (រហូតដល់សូន្យ) ប្រសិនបើសំវិធានធនតាមច្បាប់បង្គរមានចំនួនស្មើគ្នា ឬទាបជាងការថយចុះតម្លៃបង្គរដែលផ្អែកតាម CIFRS for SMEs ។ ទុនបម្រុងតាមច្បាប់ត្រូវបានតម្កល់ទុកមួយឡែកជាទ្រនាប់ដើមទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឱ្យរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (ត្រូវបន្ត)

2.20 សម្ព័ន្ធភាគី

ភាគីត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយក្រុមហ៊ុន ប្រសិនបើភាគីណាមួយមានសមត្ថភាពដោយផ្ទាល់ ឬដោយប្រយោល ដើម្បីគ្រប់គ្រងភាគីម្ខាងទៀត ឬមានឥទ្ធិពលយ៉ាងសំខាន់លើភាគីម្ខាងទៀតក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ។ សម្ព័ន្ធភាគគីអាចជាបុគ្គល ឬអង្គភាពសាជីវកម្ម ហើយរួមបញ្ចូលសមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គលណាម្នាក់ដែលត្រូវបានចាត់ទុកថាជាសម្ព័ន្ធភាគគី។

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និយមន័យនៃភាគីពាក់ព័ន្ធរួមមានភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងហោចណាស់ 10 ភាគរយនៃដើមទុនរបស់ក្រុមហ៊ុន ឬមានសិទ្ធិបោះឆ្នោត ហើយរួមបញ្ចូលបុគ្គលណាម្នាក់ដែលចូលរួមក្នុងការគ្រប់គ្រងរដ្ឋបាល ទិសដៅ ការចាត់ចែង ឬការគ្រប់គ្រងផ្នែកក្នុងរបស់ក្រុមហ៊ុន។

3. ការវិនិច្ឆ័យ និង ការប៉ាន់ប្រមាណលើគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត់ និងការវិនិច្ឆ័យ ដែលអាចប៉ះពាល់ដល់ចំនួនទឹកប្រាក់នៃទ្រព្យសកម្ម និងបំណុលដែលបានរាយការណ៍។ ការប៉ាន់ស្មាន និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកលើព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ការប៉ាន់ស្មានទាំងអស់នេះអាចខុសពីលទ្ធផលជាក់ស្តែង។

(i). ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនកត់ត្រាសំវិធានធនសម្រាប់ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃឥណទានត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ផ្អែកលើការវាយតម្លៃចំពោះការប្រមូលមកវិញបាន។ ទន្ទឹមនឹងពេលដែលគណៈគ្រប់គ្រងបានអនុវត្តតាមស្តង់ដារគណនេយ្យ គណៈគ្រប់គ្រងក៏បានធ្វើការវិនិច្ឆ័យលើកត្តាអនាគត និងកត្តាសំខាន់ផ្សេងៗទៀត ដែលទាក់ទងនឹងការប៉ាន់ស្មានចំនួនទឹកប្រាក់ និងពេលវេលានៃលំហូរសាច់ប្រាក់ ក្នុងសំវិធានធនសម្រាប់ការការថយចុះតម្លៃនៃឥណទានត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ។ ក្នុងចំណោមកត្តានានាដែលបានពិចារណា រួមមានការធ្វើចំណាត់ថ្នាក់portfolioឥណទានត្រូវទទួលរបស់ក្រុមហ៊ុន ចំណុចនៃការមិនសងត្រឡប់មកវិញនៃឥណទានត្រូវទទួលមិនដំណើរការ ផលប៉ះពាល់រួមរបស់អ្នកខ្ចី គំរូអាជីវកម្មរបស់អតិថិជន សមត្ថភាពក្នុងការបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចក្នុងការសងបំណុល ព្រមទាំងចំនួនសរុប និងចំណាត់ថ្នាក់នៃបំណុលរបស់ម្ចាស់ឥណទានផ្សេងទៀត ។

3. ការវិនិច្ឆ័យ និង ការប៉ាន់ប្រមាណលើគណនេយ្យសំខាន់ៗ (ត្រូវបានកែតម្រូវ)

(ii). អចលនទ្រព្យ និង បរិក្ខារ

គណនេយ្យសម្រាប់អចលនទ្រព្យ និងបរិក្ខារពាក់ព័ន្ធនឹងការប្រើប្រាស់ការប៉ាន់ប្រមាណសម្រាប់កំណត់អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មទាំងនេះ។ ការកំណត់អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មគឺផ្អែកលើការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង។

(iii). ពន្ធលើប្រាក់ចំណេញ

ពន្ធត្រូវបានគេគណនា តាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទបញ្ញត្តិពន្ធដារ ។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសំរេចជាចុងក្រោយលើចំនួនពន្ធនឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង ភាពលំអៀងនេះនឹងធ្វើអោយប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនលើពន្ធពន្យារនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលការកំណត់ពន្ធបានធ្វើឡើង ។ កត្តាទាំងនេះអាចបង្កើតឱ្យមានការប៉ះពាល់ពន្ធជាសារវន្ត៍ចំពោះក្រុមហ៊ុន ។ ថ្នាក់ដឹកនាំជឿថាពួកគេបានយល់ពីបទប្បញ្ញត្តិពន្ធពាក់ព័ន្ធ និងបានកត់ត្រាបំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធបច្ចុប្បន្នរបស់ពួកគេ។

4. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សាច់ប្រាក់ក្នុងដៃ*	30,423	125,251	-	-
	30,423	125,251	-	-

(*)សូមពិនិត្យចំណុច "មូលដ្ឋានលើមតិរបស់សវនករឯករាជ្យ"

5. ប្រាក់បញ្ញើនៅធនាគារនានា

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណនីចរន្ត	67,593	278,280	102,255	416,587
	67,593	278,280	102,255	416,587

6. ប្រាក់តំកល់តាមច្បាប់

ស្របទៅតាមប្រកាសលេខ 7-06-209 ចុះថ្ងៃទី 13 ខែ កញ្ញា ឆ្នាំ 2006 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរក្សានៅធនាគារជាតិនៃកម្ពុជានូវប្រាក់តំកល់លក្ខន្តិកៈចំនួន 5 ភាគរយនៃដើមទុនដោយទទួលបានកំរៃការប្រាក់ ។ ប្រាក់តំកល់លក្ខន្តិកៈនេះនឹងត្រូវប្រគល់អោយទៅក្រុមហ៊ុន នៅពេលដែលមានការជំរះបញ្ជីដោយស្មគ្រ័ចិត្ត ដោយគ្មានបំណុលប្រាក់បញ្ញើសេសសល់។

ប្រាក់តំកល់លក្ខន្តិកៈជាប្រាក់រៀលទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (1/2) នៃអត្រាការប្រាក់ដុលហិរញ្ញប្បទានដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយៈពេល 6 ខែម្តង។ ប្រាក់តំកល់លក្ខន្តិកៈជាដុល្លារអាមេរិកទទួលបានកំរៃការប្រាក់បីភាគប្រាំបី (3/8) នៃអត្រា SIBOR ក្នុងរយៈពេល 6 ខែម្តង។

7. ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានឯកត្តជន	5,225,905	21,515,051	73,450	299,235
	5,225,905	21,515,051	73,450	299,235

គ្មានប្រាក់កម្ចីណាមួយរបស់ក្រុមហ៊ុនដែលផ្តល់ដល់អតិថិជនរបស់ខ្លួនត្រូវបានចាត់ទុកថាជាប្រាក់កម្ចីមិនដំណើរការនៅចុងឆ្នាំនោះទេ ហេតុដូច្នេះហើយមិនមានប្រាក់អនុញ្ញាតសម្រាប់ប្រាក់កម្ចីដែលសង្ស័យត្រូវបានផ្តល់ដោយអ្នកគ្រប់គ្រងនោះទេ។

ឥណទានផ្តល់ដល់អតិថិជន-ដុល ត្រូវបានវិភាគដូចខាងក្រោម៖

ក. តាមកាលកំណត់៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លើសពី 1 ឆ្នាំ	1,288,968	5,306,681	13,419	54,669
លើសពី 5 ឆ្នាំ	3,936,937	16,208,370	60,031	244,566
	5,225,905	21,515,051	73,450	299,235

7. ឥណទានផ្តល់ជល់អតិថិជន-សុទ្ធ(តពីទំព័រមុន)

ខ. តាមផ្នែកសេដ្ឋកិច្ច៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សេវាកម្ម	3,631,022	14,948,918	23,358	95,160
លំនៅដ្ឋាន	1,594,883	6,566,133	50,092	204,075
	5,225,905	21,515,051	73,450	299,235

គ. តាមទំនាក់ទំនង៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
អតិថិជនខាងក្រៅ	5,215,541	21,472,382	73,450	299,235
បុគ្គលិក	10,364	42,669	-	-
	5,225,905	21,515,051	73,450	299,235

ឃ. តាមប្រភេទរូបិយប័ណ្ណ៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ដុល្លារអាមេរិក	5,225,905	21,515,051	73,450	299,235
ប្រាក់រៀល	-	-	-	-
	5,225,905	21,515,051	73,450	299,235

ង. តាមហានិភ័យ៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពុំមែនហានិភ័យធំៗ	5,225,905	21,515,051	73,450	299,235
	5,225,905	21,515,051	73,450	299,235

7. ឥណទានផ្តល់ជល់អតិថិជន-សុទ្ធ(តពីទំព័រមុន)

ច. តាមរយៈពេលកំណត់៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កម្ចីដែលមានរយៈពេលវែង				
< 30 ថ្ងៃ	5,205,222	21,429,899	73,450	299,235
≥ 30 ថ្ងៃ - 89 ថ្ងៃ	20,683	85,152	-	-
	5,225,905	21,515,051	73,450	299,235

ឆ. តាមអត្រាការប្រាក់(ក្នុងមួយឆ្នាំ)៖

	31 ធ្នូ 2022	31 ធ្នូ 2021
អតិថិជនខាងក្រៅ	12% - 15.6%	12% - 15.6%
កម្ចីបុគ្គលិក	12%	-

8. ទ្រព្យសកម្មផ្សេងៗ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បញ្ញើជាមួយសម្ព័ន្ធភាគី	-	-	675,577	2,752,301
ប្រាក់បញ្ញើ	50,150	206,467	50,150	204,311
ការបង់ប្រាក់ជាមុន	7,025	28,922	-	-
	57,175	235,389	725,727	2,956,612

9. អចលនទ្រព្យ

2022	ការកែលម្អអាគារជួល	គ្រឿងសង្ហារិម និងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារពត៌មានវិទ្យា	សរុប
តម្លៃដើម	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក
នាថ្ងៃទី 1 មករា 2022	44,683	18,156	7,275	80,827	150,941
ការទិញបន្ថែម	840	320	350	2,850	4,360
ការលុបចោល	-	-	-	-	-
នាថ្ងៃទី 31 ធ្នូ 2022	45,523	18,476	7,625	83,677	155,301
រំលស់បង្គរ					
នាថ្ងៃទី 1 មករា 2022	6,092	2,111	1,422	15,570	25,195
រំលស់សម្រាប់ការិយបរិច្ឆេទ	11,297	3,631	1,784	19,944	36,656
ការលុបចោល	-	-	-	-	-
នាថ្ងៃទី 31 ធ្នូ 2022	17,389	5,742	3,206	35,514	61,851
តម្លៃយោង					
នាថ្ងៃទី 31 ធ្នូ 2022	28,134	12,734	4,419	48,163	93,450
សមមូលជាពាន់រៀល	115,828	52,426	18,193	198,287	384,734

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាតាត្រា យែតីថល ម.ក
កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
ការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022

9. អចលនទ្រព្យ (តពីទំព័រមុន)

2021	ការកែលម្អអាគារជួល	គ្រឿងសង្ហារិម និងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារពត៌មានវិទ្យា	សរុប
តម្លៃដើម	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក
នាថ្ងៃទី 1 មករា 2021	382	1,445	3,031	1,807	6,665
ការទិញបន្ថែម	44,683	18,156	7,275	80,828	150,942
ការលុបចោល	(382)	(1,445)	(3,031)	(1,808)	(6,666)
នាថ្ងៃទី 31 ធ្នូ 2021	44,683	18,156	7,275	80,827	150,941
រំលស់បង្គរ					
នាថ្ងៃទី 1 មករា 2021	256	1,266	2,728	1,719	5,970
រំលស់សម្រាប់ការិយបរិច្ឆេទ	6,117	2,157	1,537	15,630	25,441
ការលុបចោល	(281)	(1,312)	(2,843)	(1,780)	(6,216)
នាថ្ងៃទី 31 ធ្នូ 2021	6,092	2,111	1,422	15,570	25,195
តម្លៃយោង					
នាថ្ងៃទី 31 ធ្នូ 2021	38,591	16,045	5,853	65,257	125,746
សមមូលជាពាន់រៀល	157,220	65,367	23,845	265,857	512,289

10. ទ្រព្យសកម្មអរូបី

ប្រព័ន្ធគ្រប់គ្រងធនាគារ	31 ធ្នូ 2022	31 ធ្នូ 2021
តម្លៃដើម	ដុល្លារអាមេរិក	ដុល្លារអាមេរិក
នាថ្ងៃទី 1 មករា	90,200	3,800
ការទិញបន្ថែម	-	90,200
ការលុបចោល	-	(3,800)
នាថ្ងៃទី 31 ធ្នូ	90,200	90,200
រំលស់បង្គរ		
នាថ្ងៃទី 1 មករា	7,517	2,319
ការទិញបន្ថែម	22,550	7,582
ការលុបចោល	-	(2,384)
នាថ្ងៃទី 31 ធ្នូ	30,067	7,517
តម្លៃយោង		
នាថ្ងៃទី 31 ធ្នូ	60,133	82,683
សមមូលជាពាន់រៀល	247,568	336,851

11. បំណុលផ្សេងៗ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
បំណុលជាមួយប្រធានក្រុមប្រឹក្សាភិបាល*	656,141	2,701,332	124,589	507,576
ចំណាយបង្គរ	8,800	36,230	8,250	33,611
បំណុលពន្ធផ្សេងៗ	183	753	183	746
បំណុលផ្សេងៗ	5,177	21,314	19	76
	670,301	2,759,629	133,041	542,009

(*) ចំនួនទឹកប្រាក់នេះគឺត្រូវបានផ្តល់អោយដោយប្រធានក្រុមប្រឹក្សាភិបាល អ្នកឧកញ៉ា ឡេង ភត្រា ដើម្បីជួយជំរុញដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ចំនួនទឹកប្រាក់នេះគឺពុំមានការប្រាក់ ជាមួយរយៈពេលគ្មានកាលកំណត់ពីការទូទាត់សង ហើយនឹងត្រូវសងវិញតាមការស្នើសុំភ្លាមៗ នៅពេលដែលក្រុមហ៊ុនមានលំហូរសាច់ប្រាក់ប្រសើរ។

12. បំណុលជាមួយសម្ព័ន្ធភាគី

នេះតំណាងឱ្យចំនួនទឹកប្រាក់ដែលត្រូវបង់ទៅឱ្យក្រុមហ៊ុន Galaxy Navatra Group Co., Ltd. ដែលជាអង្គភាពពាក់ព័ន្ធក្នុងអាជីវកម្មអចលនទ្រព្យ។ ជាក់ស្តែង នៅពេលដែលក្រុមហ៊ុនផ្តល់ប្រាក់កម្ចីដល់អតិថិជនរបស់ខ្លួន ប្រាក់កម្ចីត្រូវបានកត់ត្រាថាជាប្រាក់ដែលត្រូវទូទាត់ទៅឱ្យ Galaxy Navatra Group Co., Ltd ។ អតិថិជនកម្ចីមិនទទួលបានប្រាក់កម្ចីដោយផ្ទាល់ទេ។ ជំនួសមកវិញ ពួកគេត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុន Galaxy Navatra Group Co., Ltd. សម្រាប់ការសាងសង់ផ្ទះសម្រាប់អតិថិជនទាំងនោះ។ មិនមានកិច្ចព្រមព្រៀងផ្លូវការសម្រាប់ការរៀបចំនេះរវាងក្រុមហ៊ុន និងភាគីពាក់ព័ន្ធរបស់ខ្លួននោះទេ។ ចំនួនទឹកប្រាក់នេះគឺគ្មានការប្រាក់ គ្មានរយៈពេលសងថេរ ហើយត្រូវបានទូទាត់នៅពេលណាដែលក្រុមហ៊ុនមានលំហូរសាច់ប្រាក់។

13. ដើមទុន

	31 ធ្នូ 2022			31 ធ្នូ 2021		
	ភាគហ៊ុន គិតជា%	ចំនួនភាគ ហ៊ុន	ទឹកប្រាក់ដុល្លារ អាមេរិក	ភាគហ៊ុន គិតជា%	ចំនួនភាគ ហ៊ុន	ទឹកប្រាក់ដុល្លារ អាមេរិក
ឧកញ៉ា ឡេង បញ្ញាពណ៌	70%	63,000	3,150,000	70%	21,000	1,050,000
លោក សេង សុខុម	30%	27,000	1,350,000	30%	9,000	450,000
	100%	90,000	4,500,000	100%	30,000	1,500,000
សមមូលនឹងពាន់រៀល			18,526,500			6,111,000

ចំនួនភាគហ៊ុនដែលបានអនុញ្ញាតសរុបមានចំនួន 30,000 ហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2022 (2021: 30,000 ហ៊ុន) ដែលមានតម្លៃ 50 ដុល្លារអាមេរិកក្នុងមួយហ៊ុន។

នៅថ្ងៃទី 18 ខែ មករា ឆ្នាំ 2021ភាគទុនិកបច្ចុប្បន្នបានចុះកិច្ចព្រមព្រៀងទិញភាគហ៊ុនជាមួយ ភាគទុនិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពន្លឺចតុមុខ អ៊ីអិលស៊ី ដើម្បីទទួលបានភាគហ៊ុនទាំងអស់ពីពួកគេ ។ សម្រាប់ការពិចារណាទិញត្រូវបានគិតបញ្ចូលនូវទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពន្លឺចតុមុខ អ៊ីអិលស៊ីរួមមានប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងប្រាក់បញ្ញើដែលធ្វើនៅធនាគារពាណិជ្ជ និងសាច់ប្រាក់ ។

នៅថ្ងៃទី 2 ខែ មីនា ឆ្នាំ 2021 ក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិ នៃកម្ពុជាទៅលើការផ្លាស់ប្តូរភាគទុនិក។នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 2021 អនុម័តលើការផ្លាស់ប្តូរភាគទុនិក និងប្តូរឈ្មោះក្រុមហ៊ុនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យៃតីថល ម.ក។

13. ដើមទុន (តពីទំព័រមុន)

ជាងនេះទៅទៀត ក្នុងកំឡុងឆ្នាំ 2022 ដើមទុនដែលបានបង់រួចរបស់ក្រុមហ៊ុនត្រូវបានកើនឡើងពី 1,500,000 ដុល្លារ ទៅ 4,500,000 ដុល្លារអាមេរិក ដែលមានចំនួន 90,000 ហ៊ុន ដែលមានតម្លៃស្មើ 50 ដុល្លារក្នុងមួយហ៊ុន។ ការបង្កើនដើមទុនត្រូវបានអនុម័តដោយ NBC នៅថ្ងៃទី 25 ខែសីហា ឆ្នាំ 2022។ នៅថ្ងៃទី 5 ខែកញ្ញា ឆ្នាំ 2022 ក្រុមហ៊ុនបានទទួលការយល់ព្រមពី MOC ក្នុងការកែប្រែកន្ទិកៈក្រុមហ៊ុន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរខាងលើ។ ភាគហ៊ុនទាំងអស់ត្រូវបានបង់គ្រប់ចំនួន។

14. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិតំណាងឲ្យភាពខុសគ្នានៃសំវិធានធនការថយចុះតម្លៃនៃឥណទានតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមប្រកាសធនាគារជាតិនៃកម្ពុជា។ នៅពេលដែលសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមប្រកាសធនាគារជាតិនៃកម្ពុជាខ្ពស់ជាងសំវិធានធនការថយចុះតម្លៃនៃឥណទានតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម ចំនួនដែលខុសគ្នានឹងត្រូវបានកត់ត្រាជាទុនបម្រុងតាមបទប្បញ្ញត្តិ។ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានផ្ទេរពីប្រាក់ចំណេញរក្សាទុក។

15. ចំណូលពីការប្រាក់

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានផ្តល់ដល់អតិថិជន	254,447	1,040,434	378	1,538
ប្រាក់បញ្ញើនៅធនាគារនានា	663	2,711	725	2,949
	255,110	1,043,145	1,103	4,487

16. ចំណាយលើបុគ្គលិក

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បៀវត្សរ៍	270,778	1,107,211	142,090	578,022
អត្ថប្រយោជន៍ផ្សេងៗ	11,882	48,586	5,746	23,375
	282,660	1,155,797	147,836	601,397

17. ចំណាយលើប្រតិបត្តិការផ្សេងៗ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយថ្លៃជួល	108,000	441,612	69,500	282,726
ចំណាយពន្ធផ្សេងៗ	21,384	87,439	6,853	27,878
ចំណាយទឹកភ្លើង	14,529	59,409	6,587	26,796
កម្រៃប្រព័ន្ធប្រចាំឆ្នាំ និងថែទាំ	13,530	55,324	13,530	55,040
ចំណាយសម្ភារៈការិយាល័យ	11,536	47,171	6,136	24,961
កម្រៃវិជ្ជាជីវៈ	10,431	42,652	10,568	42,991
អាជ្ញាប័ណ្ណអាជីវកម្ម និងពន្ធក្នុងស្រុក	8,117	33,190	5,683	23,118
ចំណាយលើប្រព័ន្ធទំនាក់ទំនង	7,864	32,156	5,642	22,952
ចំណាយលើសេវាសន្តិសុខ	5,278	21,582	1,761	7,164
ចំណាយលើសេវាធនាគារ	57	233	8,138	33,105
ចំណាយផ្សេងៗ	7,731	31,613	4,565	18,570
ចំណាយជួសជុល និងថែទាំ	-	-	340	1,383
ចំណាយធ្វើដំណើរ	-	-	81	330
ចំណាយការលុបចោលទ្រព្យសកម្ម	-	-	1,867	7,595
	208,457	852,381	141,251	574,609

ពន្ធលើប្រាក់ចំណេញ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	2,572	10,517	21	85
	2,572	10,517	21	85

ក. ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

អនុលោមតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញដោយគណនាតាមអត្រា20%នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បរមាដោយគណនាតាមអត្រា1%នៃប្រាក់ចំណូលនៅពេលដែលពន្ធមួយណាមានចំនួនធំជាង។

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ខាតមុនបង់ពន្ធ	(293,114)	(1,198,543)	(318,858)	(1,297,115)
ពន្ធលើប្រាក់ចំណេញក្នុងអត្រា20%	(58,623)	(239,709)	(63,772)	(259,424)
ខ្ទង់ចំណាយមិនអាចកាត់កងបានតាមច្បាប់សារពើពន្ធ	17,585	71,905	8,349	33,962
ទ្រព្យសកម្មពន្ធពន្យារមិនទទួលក្នុងឆ្នាំ	52,354	214,075	68,369	278,126
ខ្ទង់ចំណាយអាចកាត់កងបានតាមច្បាប់សារពើពន្ធ	(11,316)	(46,271)	(12,946)	(52,664)
ចំណេញពន្ធលើប្រាក់ចំណេញ@20%	-	-	-	-
ពន្ធអប្បបរមាក្នុងអត្រា 1%	2,572	10,517	21	85

18. ពន្ធលើប្រាក់ចំណេញ (តពីទំព័រមុន)

ក. ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ (តពីទំព័រមុន)

បម្រែបម្រួលនៃពន្ធពន្យារជាបំណុល មានដូចខាងក្រោម៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យដើមគ្រា	-	-	192	776
បម្រែបម្រួលក្នុងឆ្នាំ	2,572	10,517	21	85
ពន្ធបានបង់ក្នុងឆ្នាំ	(2,053)	(8,395)	(30)	(122)
សំវិធានធនប្តូរជាបំណុលផ្សេងៗ	-	-	(183)	(746)
លម្អៀងពីការប្តូរូបិយប័ណ្ណ	-	15	-	7
សមតុល្យចុងគ្រា	519	2,137	-	-

ការខាតបង់ពន្ធយោងទៅមុខ

នៅកាលបរិច្ឆេទតារាងតុល្យការ ក្រុមហ៊ុនបានប៉ាន់ប្រមាណការខាតបង់ពន្ធចំនួន 611,219 ដុល្លារ ឬ 2.5 ពាន់លានរៀល (ឆ្នាំ 2021៖ 449,805 ដុល្លារឬ 1.83 ពាន់លានរៀល) ដែលអាចរកបានសម្រាប់ទូទាត់ធៀបនឹងប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។

ក្រុមហ៊ុនមានសិទ្ធិយកការខាតបង់ពន្ធបុគ្គលនីមួយៗទៅមុខ ដើម្បីទូទាត់ទល់នឹងប្រាក់ចំណេញជាប់អាករដែលកើតឡើងក្នុងរយៈពេលប្រាំ (5) ឆ្នាំបន្តបន្ទាប់នៃឆ្នាំដែលការខាតបង់នេះបានកើតឡើង។ ក្រុមហ៊ុនមិនបានទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារពីការខាតបង់ពន្ធបន្តទេ ដោយសារអ្នកគ្រប់គ្រងជឿថាមិនមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ដែលនឹងអាចរកបានប្រឆាំងនឹងការដែលនេះអាចប្រើប្រាស់បាន។

19. សមតុល្យ និងប្រតិបត្តិការសម្ព័ន្ធភាគី

ប្រតិបត្តិការជាមួយនឹងសម្ព័ន្ធភាគីគឺមានដូចខាងក្រោម៖

ប្រតិបត្តិការសម្ព័ន្ធភាគីជាមួយក្រុមហ៊ុននៅក្រោមការគ្រប់គ្រងតែមួយ ៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក្រុមហ៊ុន Galaxy Navatra Group				
ចំនួនត្រូវទទួលបាន	-	-	675,577	2,752,301
ចំនួនត្រូវបង់ទៅឱ្យ	1,333,334	5,489,336	-	-

ប្រតិបត្តិការសម្ព័ន្ធភាគីជាមួយនឹងអ្នកគ្រប់គ្រងសំខាន់ៗ

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
បំណុលជាមួយប្រធានក្រុមប្រឹក្សាភិបាល				
អ្នកឧកញ៉ា ឡេង ភត្រា	656,141	2,701,332	124,589	507,576

20. កិច្ចសន្យា និងផែនទ្រព្យអកម្ម

(i) ភតិសន្យាប្រតិបត្តិការ

ក្រុមហ៊ុនបានចុះកិច្ចសន្យាសម្រាប់ជួលអគារការិយាល័យកណ្តាលរបស់ខ្លួន និងការិយាល័យសាខាជាមួយភាគីដទៃទៀតតាមភតិសន្យាជួលដែលបានរៀបចំជាមួយតម្លៃភតិសន្យាអប្បបរមានាពេលអនាគតដូចខាងក្រោម៖

	31 ធ្នូ 2022		31 ធ្នូ 2021	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពី 1 ទៅ 5 ឆ្នាំ	118,800	485,773	118,800	483,991
លើសពី 5 ឆ្នាំ	277,200	1,133,471	396,000	1,613,304
	396,000	1,619,244	514,800	2,097,295

20. កិច្ចសន្យា និងផែនទ្រព្យអកម្ម (តពីទំព័រមុន)

(ii) ផែនទ្រព្យអកម្មលើពន្ធ

ពន្ធត្រូវបានគណនាផ្អែកលើមូលដ្ឋាននៃការបកស្រាយនៃបទប្បញ្ញត្តិពន្ធនាពេលបច្ចុប្បន្ន។ ការអនុវត្តច្បាប់ពន្ធដារ និងបទបញ្ញត្តិផ្នែកពន្ធដារចំពោះប្រតិបត្តិការមួយចំនួនអាចត្រូវបកស្រាយដោយខុសពីគ្នា នៅពេលមានការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។ ការវិនិច្ឆ័យរបស់ក្រុមហ៊ុនលើប្រតិបត្តិការជំនួញរបស់ខ្លួនអាចមានភាពខុសគ្នាពីការវិនិច្ឆ័យដែលធ្វើឡើងនៅពេលមានការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារទាំងនោះ។ ក្នុងករណីនេះ ក្រុមហ៊ុននឹងរងការកំណត់ពន្ធបន្ថែម ការផាកពិន័យ និងការប្រាក់យឺតយ៉ាវដែលអាចមានជាសារវន្ត។ ដូចច្នេះ ចំនួនដែលកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះអាចនឹងមានការកែប្រែនាពេលអនាគតនៅពេលដែលមានការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

21. ផលប៉ះពាល់នៃ Covid-19

ចាប់តាំងពីថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ដោយសារការផ្ទុះឡើងនៃ Covid-19 បានធ្វើអោយប៉ះពាល់ដល់ដំណើរការអាជីវកម្មជាច្រើននៅទូទាំងប្រទេស។ ថ្នាក់ដឹកនាំបានវាយតម្លៃពីផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប៉ុន្តែមិនអាចវាយតម្លៃពេញលេញនូវហានិភ័យនេះនាកាលបរិច្ឆេទនៃរបាយការណ៍នេះឡើយ។ រយៈពេល និងផលប៉ះពាល់របស់ Covid-19 នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយទេនៅពេលនេះ។ រយៈពេល ភាពធ្ងន់ធ្ងរនៃផលវិបាក និងការប៉ះពាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុននាពេលអនាគតមិនអាចធ្វើការសន្និដ្ឋានអោយជាក់លាក់បានទេ ។ ថ្នាក់ដឹកនាំគិតពិចារណាថាផលប៉ះពាល់ចម្បងដែលកើតឡើងពីការផ្ទុះឡើងនៃ Covid-19 មិនមានរយៈពេលវែងនោះទេ ហើយសកម្មភាពរបស់ក្រុមហ៊ុនអាចមានភាពយឺតយ៉ាវក្នុងរយៈពេលនេះដែលអាចប៉ះពាល់ដល់កំរិតផលចំណេញ និងសន្ទនិយភាព ប៉ុន្តែនឹងមិននាំឱ្យមានបញ្ហាលើនិរន្តរភាពនៃដំណើរការអាជីវកម្មនោះទេ។

ក្រុមហ៊ុនបានធ្វើការវាយតំលៃព្រឹត្តិការណ៍បន្ទាប់នាចុងការិយបរិច្ឆេទរបាយការណ៍រហូតដល់ថ្ងៃចេញរបាយការណ៍ហិរញ្ញវត្ថុ។ ថ្នាក់ដឹកនាំក្រុមហ៊ុនបានកំណត់ថា ព្រឹត្តិការណ៍ទាំងនេះគឺមិនជាព្រឹត្តិការណ៍ដែលទាមទារអោយមានការកែតំរូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

22. ព្រឹត្តិការណ៍បន្ទាប់ពីការអោយការណ៍ចុងគ្រា

មិនមានព្រឹត្តិការណ៍កែសម្រួល និងព្រឹត្តិការណ៍មិនកែសម្រួលសំខាន់ៗណាមួយ បានកើតឡើងចន្លោះ និងថ្ងៃដែលបានអនុម័តអោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនោះទេ។

LENG NAVATRA CAPITAL PLC

ត្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឡេង ណាវ៉ាត្រា យ៉ៃកីថល ម.ក

អាសយដ្ឋាន : អគារ H07B ផ្លូវ អូស៊ីអាយស៊ី ភូមិ គៀនឃ្លាំង សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានី ភ្នំពេញ

ទូរស័ព្ទលេខ :០២៣ ៩៣ ៦២២២

គេហទំព័រ :www.Lengnavatracapital.com.kh

សារអេឡិចត្រូនិក : info@lengnavatracapital.com.kh